# រឿងចំប៉ាថោង ៤



B.5
C.375
N.2888

ន-ន
108

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គីម-គី

| | | |
|---|---|---|
| ច្បាប់បវឡាន . . . . . . . . . . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . . . . | ,, | ៨៛០០ |
| គេដោជំឌិន ទី ១ ដល់ទី ៧ ចប់ . . . . . | ,, | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . . . . . . | ,, | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . . . . . . . | ,, | ៦៛០០ |
| រឿងធន្ធមឿង ទី ១ ទី ២ ចប់ . . . . . | ,, | ៨៛០០ |
| រឿងធ្មេញជ័យ . . . . . . . . . . | ,, | ១២៛០០ |
| រឿងអាឡាដាំងមនុស្សមាត់ទិព្វចង្កៀងទិព្វ . | ,, | ១៤៛០០ |
| រឿងព្រះសុធន នាងកែវមនោរា ទី ១ ទី ២ ចប់ | ,, | ៩៛០០ |
| រឿងវិបុលស្គ្រាមទី ១ . . . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ . . . . . . . . | ,, | ១៤៛០០ |
| ,, ,, ទី ៣ . . . . . . . . . . | ,, | ១២៛០០ |
| នាងពីរជណ្តាប់ ពុទ្ធសែននាងកង្រី . . . | ,, | ១០៛០០ |
| ព្រះបន្ទូគោរប់ ទី ១ ទី ២ . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ៣ ចប់ . . . . . . . | ,, | ១២៛០០ |
| បងប្អូនពីរនាក់ . . . . . . . . . | ,, | ១០៛០០ |
| ក្បួនទាយទឹងសំឡេកផ្សេងៗ . . . . . | ,, | ១៥៛០០ |
| ច្បាប់បង្ហាត់ទាហាន . . . . . . . . | ,, | ៥៛០០ |
| រឿងជ័យសុវង្ស ទី ១ ដល់ ទី ៤ ចប់ . . | ,, | ១០៛០០ |
| រឿងព្រះមហោសថ ទី ១ . . . . . . . | ,, | ១០៛០០ |
| ,, ,, ទី ២ ទី ៣ . . . . | ,, | ៨៛០០ |

1953 - 4



B- A- 435



នាងខឹងធុញថប់ គិតសប់គឺតគ្រប់ ស្អប់នាងសុវណ្ណា

ខ្វាន់ខ្វាញ់ខ្វាញ់ខ្វល់ រំជួលចិន្តា ស្អប់ស្អាត់ក្ត្រា

អន់អាក់ចិត្តក្រៃ ៗ សម្តេចភូមី ទតទៅទេវី

ម្ហេសីនោះនៃ ស្ដេចជ្រាបជាអាក់ ថ្នាំងថ្នាក់ព្រះទ័យ

ក្សត្រាដៀសដៃ ពុំចេញបរបារ ៗ លុះចូលរាត្រី

សម្តេចចក្រី ស្ដែងស្ដេចលីលា ចរចាកនាងនាថ

សង្សាស្នេហា ទៅឋានធិតា ប្រាំពីរនោះនៃ ៗ

## នេះបទព្រហ្មគីត

ព្រះអង្គថ្នមបបក់ ប្រលឹងអ្នកមាសប្អូនតង់

អង្អែលព្រះសុជន បីត្រកងអស់អង្គស្រី ៗ

ដាក់លើទទេវត ស្ពាលស្នែស្និតមូលមេត្រី

ព្រះទិសថ្ងៃប្រឹមប្រិ បន្ទូលទៅឋាននាងណា ៗ

ហៃប្អូនមាសត្រកាល មាសសង្សាស្គាប់បងព

មាសសើយបងនេះណា វែងធារស្ដិរ៉ងថប់ក្រៃ ៗ

ក្រែងប្អូនស្ងួនរីវល័ក្ស នាងអន់អាក់ព្រះហឫទ័យ

ចិត្តបងប៉ងសព្វថ្ងៃ ពិតពុំឲ្យអាសាសោត ៗ

កុំប្អូនមាសប្រលឹង មោហខឹងបងចិត្តក្រោធ

បងពុំតើកកួត ពីបុរាណមិនមោសា ៗ

សូមប្អូនមាសបន្ទូល ព្រមអនុកូលមូលនូវគ្នា

អាសូរសុវណ្ណា អង្គឯកាឥតសន្តាន ៗ
ប្រាំពីរនាងនារី ថ្វាយវន្ទីក្សត្រប្រធាន
នាងទូលថាសូមទាន ស្តេចកុំព្រួយព្រះហឫទ័យ ៗ
បពិត្រព្រះភូធរ យើងខ្ញុំអរទីងស្រីថ្លៃ
កុំព្រះអង្គសង្ស័យ ចិត្តយើងខ្ញុំតាំងនេះណា ៗ
ខ្ញុំទុកស្នេហ៍ជីវី បង្កើតសិរសោគ្រប់គ្នា
ស្ងួនគ្រងរួមរក្សា លុងលុះអស់ជនជីវ៍ ៗ
ក្សិណណ្ណាះព្រះភូបាល ស្តាប់នាងនាថមូលមេត្រី
ស្នានស្នោះដូចសំដី ស្តេចទ្រង់ក្សានព្រះទេយ្យ ៗ
ត្រាស់ថាហៃប្អូនតន់ បងអរលន់ទឹងស្ងួនក្ង៉ា
ចិត្តប្អូនមានមេត្តា ព្រមអនុកូលមូលមេត្រី ៗ
ហើយព្រះអង្គប្រា៉ ឱបអង្គាព្រះប្អូនស្រី
ថើបថៃរព្រះភក្ត្រខ្ញី រួមប្ទុំទឹងនាងណា ៗ
ព្រះហស្តកៀកកាន់កោះ អង្អែលផោះនាងធិតា
ត្រួតត្រិតជិតឱប ពិតពុំមានមន្ទិលហ្មង ៗ
ហើយស្តេចលោមនាងថា ស្ងួនសង្ខ្យាមាសស្នេស្នង
បងលាប្អូនទៅហោង ចូលនាងនៅណាមាសថ្លៃ ៗ
ព្រះឱសទ្រង់ចរចារ ហើយលើលាវិលវឹងវៃ
ស្តេចថ្កានាងនាថនៃ ដល់ប្ទុំកាលណោះណា ៗ

ស្តេចខិតចូលជិតខាង ឱបអង្គនាងសុវណ្ណា
ព្រះឱស្ឋថ្លៃថ្លែងថា ដោយនូវពាក្យពីរសំដី ៗ
ហៃប្អូនស្ងួនវល្លិ មាសមេអាក់អន់ទឹងអ្វី
យល់ពុំដូចប្រក្រតី សព្វមួយដងមកឡើយណា ៗ
ព្រះភក្ត្រស្រស់ប៉ប្រែ ហាក់វិសែព្រះចន្ទ្រា
រីឯរះពីបូពា ក៏សន្លោសន្លៅឆ្ងាយ ៗ
ឥឡូវស្តេចក្រៀមក្រំ មាសឧត្តមពុំកែកាយ
ប្អូនមួយមាសឆោមឆាយ ចឹងទឹងបងណានាងអើយ ៗ
នាងស្តាប់ព្រះរាជា វរធិតាទូលឆ្លាស់ឆ្លើយ
បពិត្រក្សត្រត្រានត្រើយ សូមស្តេចជ្រាបព្រះទេយ្យា ៗ
ប្អូនឥតបើឆ្គិឆ្គង ខានចឹងផងព្រះរាជា
កុំព្រះអង្គសង្ការ កុំមន្ទិលទឹងប្អូនស្រី ៗ
ទោះបីព្រះអង្គក្សត្រ ស្តេចប្រតិព័ទ្ធស្ងួនបេត្តី
ទឹងអ្នកណានោះក្តី តាមព្រះទៃព្រះរាជា ៗ
ខ្ញុំពុំអាចខឹងខាន ប្រែប្រែងាករិះឫស្យា.
កុំព្រួយព្រះចិន្តា ក្រែងប្អូនធ្លោយដោយចិត្តពាល ៗ
ប្អូនពុំដូចស្រីគេ គិតរិះរេស្រើបស្រែស្រោល
សូមមានព្រះភូបាល កុំទ្រង់ព្រួយព្រះទ័យា ៗ
ខ្លួនប្អូននេះសូមផ្ញើ ជីវិតលើព្រះរាជា

| | | |
|---|---|---|
| ទោះក្រៃផន្ទា | ប្អូនផ្ញើខ្មោចនឹងព្រះបង | ៗ |
| ស្តេចស្តាប់នាងទេវី | ព្រះភូមីបន្ទូលស្នង | |
| ហៃប្អូនស្ងួនមាសបង | ពិតពីរោះដោយធម៌ថា | ៗ |
| បងទៅឯនាងស្រី | ទាំងប្រាំពីរអង្គនោះណា | |
| សូមនាងមានមេត្តា | ទុកជាតាះស្នើជីវី | ៗ |
| នាងស្តាប់ព្រះមហាក្សត្រិយ៍ | ហើយនាងនាថសងមេត្រី | |
| បពិតព្រះចក្រី | កុំស្តេចថប់ត្រង់នេះណា | ៗ |
| សព្វថ្ងៃប្អូនជាខ្ញុំ : | ព្រះឧត្តមម្ចាស់សិរសា | |
| ទោះខុសគាប់ចិន្តា | សូមព្រះអង្គប្រោសប្រណី | ៗ |
| ដូចពោធិព្រឹក្សមាសមាន | មែកយោនយានស្រោមស្លឹកខ្ចី | |
| អាស្រៃជាប្រក្រតី | ពិតពឹងពំនាក់នូវឆ្ងាយ | ៗ |
| ទោះក្តៅក្តាត់ក្តីណា | ជ្រករុក្ខាបាត់ក្រហាយ | |
| សឹងបានសុខសប្បាយ | បរបូរពិតបុណ្យភូមី | ៗ |
| ម្តេចឡើយក៏ហ៊ានហែក | កាប់កាច់មែកត្រួលត្រួយខ្ចី | |
| រិចរិលកំដៅថ្ងៃ | សោកសឹងត្រូវអង្គអាត្មា | ៗ |
| ដំណើរទាំងនេះហោង | កុំព្រះបងស្តេចសង្កា | |
| ខ្ញុំពុំទូលមុសា | ពិតពីពោះដូច្នេះនៃ | ៗ |
| ស្តេចស្តាប់ពជតន្និតា | ព្រះភជាពេញហឫទ័យ | |
| ត្រេកអរឯងពេកក្រៃ | នឹងនាងនាថសុវណ្ណា | ៗ |

ហៃប្អូនស្ងួនលក្ខ　　កែវកុំអាក់អន់ចិន្ដា
បងចង់ដឹងទេយ៉ា　　តើនាងប្រកាន់ឬទេ ។
មាសសើយបងគិតគ្រប់　　ដោយនៅចាប់ពុំវៀចវេ
ព្រះទ័យដូចមាសស្ងួ　　នេះពេញគាប់ប្រសើរក្រៃ ។
ហើយទើបព្រះចោមចៅ　　ត្រាស់ឲ្យហៅនាងនាថថ្លៃ
ប្រាំពីរមកដល់នៃ　　ថ្វាយបង្គំព្រះរាជា ។
ទើបស្ដេចបន្ទូលថ្វី　　បំណែកស្រីសុវណ្ណា
បងផ្ញើលើភល់គ្នា　　ទាំងប្រាំពីរនាងនារី ។
- តោះបីនាងផ្គំផ្គង　　មានមេហោងស្មើជិនី
បងទុកប្អូនពីសី　　ជាតិជាប្រុងអស់ទេះណា ។
នាងឮស្ដេចបង្គាប់　　នាងគោរពវន្ទា
នៃនាងសុវណ្ណា　　ព្រមទទួលតាមព្រះទ័យ ។
នាងសុវណ្ណបំប៉ា　　ព្រមចិន្ដាមិត្តមូលមៃ
ត្រិះត្រែកអរពេកក្រៃ　　ពីព្រះភក្ត្រហាក់ចន្ទ្រា ។
ស្មានស្មោះដូចបំណង　　ពុំមានបងចិត្តក្រោធា
ពុំដឹងកលមាយា　　នាងប្រាំពីរប៉ុនកេសី ។

## នេះបទកាកគតិ

ស្ដេចសោយរាជស្កល់　　រាស្ត្រជួមនល់　　ហេមន្ដធានី
ហោរាព្រាហ្មណ៍ព្រឹទ្ធ　　បណ្ឌិតកវី　　អាមាត្យមន្ត្រី

ទាហានអាសា ។ ប្រជាជនផង កួយពន្ធស្បៀងផង
ចុងស្រុកក្តីណា ទាំងអ្នកនគរ រីរត្រៀបត្រា
ឥតមានភ័យ្រា ថ្កើងថ្កានផាប់ក្រៃ ។ ដោយបុណ្យព្រះបាទ
នូវនាងននាថ សុវណ្ណថ្លាថ្លៃ កើតសោភ័ទី
បូរីនោះនៃ នគរដទៃ មូលមកវន្ទា ។
ក្សត្រថ្លៃប្រុះប្រុង ស្តែងស្តេចនូវសង គុណនាងវិទ្យា
គិតកាលកំសត់ រួតរត់យាត្រា តាមរាជធិតា
ចាកចោលបូរី ។ តែពីរអង្គា ពុំមានអ្នកណា
មួយមកកក្រក្ដី ទ្រង់ព្រះរាជទាន សឹងពានសុវណ្ណី
ដល់វីទ្យាវៃ ពុំខ្វះឡើយណា ។ ខ្វល់ខ្វើយពូកព្រំ
រាំងននបៀមបំ មុងមាសសោភា គ្រែគ្រឹះដំណេក
តែងដេកសព្វគ្រា ទ្រព្យថ្លៃជា ១ សឹងល្អស្ចារ្យ ។
រីព្រះមហេសី រួមរាក់មេត្រី ស្រឡាញ់វិទ្យា
ពុំដែលឲ្យអាក់ ថ្នាំងថ្នាក់បិត្តា ពុំឲ្យនរណា
ស្តីលើឡើយនៃ ។ ក្សត្រាទ្រើសទ្រង់ ពាលពេញរៀនវគ្គ
រឹងរិតជាញដៃ នូវទឹងនាងនាថ សង្ក្រាថ្មីថ្លៃ
លុងលុះតិចនៃ នាងសព្វឯកា ។ យល់ព្រះដៀសដៃ
សព្វព្រះហឫទ័យ នាងសុវណ្ណា និយាយក្សិបក្សៀវ
កេះកៀវបរបា ថាខ្ញុំអាត្មា យើងហើយនេះម្តង ។

លោកបានប្រពន្ធ លោកស្រឡាញ់លន់ លើសអស់យើងផង
យើងអើយអាសា ឥតការទេហោង គិតហើយរឹងចង
ចិត្តក្រៃក្រោធា ៗ ជាឪប្តីអញ កំពុងស្រឡាញ់
មារមកបង់ឃ្វា បង់ឃ្វាតដល់ដោយ មិនឲ្យជុំគ្នា
យកជាប្តីវា ស្នាលស្និតមេត្រី ៗ ស្តេចសោតរំងួង
ពិតពុំជ្រាបឆ្វេង ភាំងភ្លេចស្មារតី ស្រឡាញ់តែគេ
ស្និតស្នេហបត្តី ក្រៃលែងប្អូនស្រី ជាខ្ញុំនេះណា ៗ
កាលដើមក្សត្រក្សាន រួមរក្សគ្រប់ប្រាណ មូលមិតស្នេហា
ឥតឡូវបែបបែក សព្វែកចិន្តា ពីដួចបានវា
ចូលចាប់ចង់ពុន ៗ បេះកលមាយា មានផ្កាចំប៉ា
ត្រកាលលើសលន់ បើដោយគំនិត ប្អូនគិតប្អូនគន់
ប្អូនរឹងអួលអន ក្នុងចិត្តចិន្តា ៗ នាងខឹងគិតគំ
ជួបគ្នាជុំនុំ លបលួចបរចារ ក្តៅក្តាត់ហាក់ភ្លើង
ឆេះឡើងសោះសា ហេតុចិត្តមោហា បាំងចិទស្មារតី ៗ
ងងិតសូន្យសល់ គុនគិតពុំយល់ បុណ្យបាបអ្វី ៗ
គិតតែម្នោម្នះ ចង់ឈ្នះសេចក្តី ប្រួតស្អប់ក្សត្រី
ប្រសើរសោកា នាងខ្វះថ្វាស់ថ្វើយ ជាហៃនាងអើយ
អស់យើងគ្រប់គ្នា បើអ្នកណាបេះ ចំណោះបរចារ
ឲ្យមានចំប៉ា ជ្រុះចេញពីមាត់ ៗ សំព្រះដៀសដៃ

សព្វព្រះហឫទ័យ　ទឹងអ្នកនោះក្ដាត់　ដូចសុវណ្ណា
ធិតាប្រាកដ　មែនមិនមានក្ងាត់　ដូចឈ្មោះឡើយណា ៗ
ឬមួយយល់ម្តេច　គន្ធិកល់កិច្ច　ឆ្លើយមកសួរ
ក្សិណ្ណាះពុំលុង　ឯអគ្គសុរិយា　ចារបែងថ្ងៃថា
អញយល់ជាបាន ៗ　យើងឲ្យជួលជាង　រចនាជំនាង
បុប្ផាមកថ្កាន　សុទ្ធសឹងបុប្ផា　សុវណ្ណកល្យាណ
ទីទៃគ្រប់ប្រាណ　ប្រាំពីរធីតា ៗ　បានរៀមក្នុងមាត់
ឡើងទៅគាល់ក្សត្រ　ក្សិណាយើងបរបារ　កាលបើកមាត់មិញ
សឹងចេញបុប្ផា　រុះពីទិស្សា　ដូចគេនោះនៃ ៗ
អ្នកខ្វះឆ្លើយស្មោះ　នាងគិតដូច្នោះ　យល់គាប់ពេកក្រៃ
អញរើងពេញចិត្ត　ឯងឥតសង្ស័យ　ច្នោះហើយចូលវៃ
តែងទៅស្រួក ៗ　ស្រេចទើបហៅខ្ញុំ　មកហើយជំនុំ
ខ្សិបខ្សៀវបរបារ　ប្រាមប្រើប្រយ័ត្ន　ប៉ិនមាត់គ្រប់គ្នា
កុំឲ្យបែកការ　ក្នុងគ្រានេះម្តង ៗ　ឯមេទាសា
ចរចេញលីលា　ដូចចិត្តបំណង　ជួលជាងរចនា
សោភាឥតហ្មង　ស្រេចហើយនាំផ្គង　ថ្វាយរាជជ័យា ៗ
នាងយល់ផ្កាផង　ដល់ដូចបំណង　ត្រេកសោមនស្សា
ញញឹមសាទរ　ឯងអរអួតថា　ទឹកញញឹងរ៉
យល់ម្តេចនេះម្តង ៗ　លុងលុះពិលា　ចូលគាល់ក្សត្រា

ទាំងនាងនោះហោង ស្អិតស្អាងអាត្មា សោភាឥតហ្មង
ក្របេះបាន់ផង លាយលាបអង្គា ៗ ស្រេចហើយក្សត្រី
សុរិយាទេវី បៀមផ្កាក្ដាំងរ៉ា ចត្ដុបុលវត្ដី
ប្រិមប្រិសោភា នាងនោះបៀមផ្កា បុះនាគសុវណ្ណី ៗ
ឯនាងសន្ធរ ស្រីស្រស់បវរ ឆោមឆាយពិសី
បៀមម្ទិះរួតវត់ ល្អក្ដាត់ឥតបី មើលហាក់ដូចក្ដី
ទិព្វទេពកញ្ញា ៗ នាងសុពានរត្ន ល្មមល្មៃល្អក្ដាត់
បៀមផ្កាកណិកា នាងសុវត្ដី ក្សត្រីថ្ងៃថ្វា
បៀមផលបូជា ផូវផង់ក្ដាត់ហោង ៗ នាងស្រីអក្ដៃ
ល្វាសល្ងន់ប្រៃពៃ ព្រះភ័ក្ត្រឆ្មៀងឈ្មង បៀមផ្កាប្រលិត
ពិចិត្តឥតហ្មង អណ្ដាប់នោះហោង នាងស្រីបូរី ៗ
នាងបៀមរំដួល មាសមែតាប់គួរ កាយគលព្រណី
សោតសឹងនុព្វគុណ ទិព្វតន់ថ្មី ៗ ផាន់បេះឲ្យដី
ក្សូក្រាប់វេចនា ៗ ស្រេចហើយក្សត្រី យាន់យាសចុះពី
លំនៅអាត្មា ញ៉ែងញ៉ង់ដជាយ កែក្រាយយាត្រា
ល្វាសល្ងន់ហត្ថា ញាំញើពេកក្រៃ ៗ ផល់រាជរោងរត្ន
ក្រញ៉ូក្រាបប្រណិបត្តិ ពីព្រះជៀសដៃ មុខមាត់ញញឹម
ប៉ប្រិមប៉ប្រិ សើចសង់ស្ងូម៉ៃ ទៅមកកាន់គ្នា ៗ
បុប្ផានោះនៃ ជ្រុះចេញអំពី ព្រះឥស្វនាងណា

ល្អៗសោភ័ណ    សុវណ្ណបុប្ផា    គ្រប់អង្គធិតា
ប្រាំពីរពិសី ៗ    ស្តុំស្ថិតទាសា    មើលយល់បុប្ផា
មាសមានរស្មី    ផណ្ដើមគ្នារើស    ប្រទើសឃ្លាតខ្លី
ក្បិណព្រះបក្រី    ស្ដេចទតទៅយល់ ៗ    ស្ដេចត្រាស់ដណ្ដឹង
ជាអស់ក្មេងទីង    រើសអ្វីរបល់    ទើបឯកាសា
វន្ទាទសពល    ទូលថាខ្ញុំយល់    សុវណ្ណបុប្ផា ៗ
ផ្ទុះចេញអំពី    ព្រះទិស្ទបក្រី    ប្រាំពីរអង្គា
យល់ផាចម្ខែក    ល្អពេកក្ដាត់ណា    សូមព្រះភជា
ផ្កាបព្រះហឫទ័យ ៗ    ក្សត្រក្សានប្រសើរ    ជឹងដោយដំណើរ
អស់នាង់នោះនៃ    ស្ដេចពុំជឿជា    បុប្ផាវិសៃ
ដោយព្រះញាណថ្ងៃ    ប្រុសព្រាយប្រាជ្ញ ៗ    នេះសំអស់នាង
គុនគិតចេះជាង    ស្អប់សុវណ្ណា    ធ្វើមកឲ្យអញ
ពិតពេញចិន្ដា    មិនគឺបុប្ផា    កើតឯងឡើយហោង ៗ
ដំណាយូរទៅ    មុខជាសំត្រូវ    នឹងនាងប្រះប្រូង
ស្រីសុវណ្ណា    ពុំហ៊ានទូនល្អង    មិនលែងឡើយហោង
ប្រាកដក្ដាត់ណា ៗ    បើនឹងថែងតាយ    ឲ្យលេចពន្ទាយ
កើតកេត្តិទិន្ន    អង្គអាស្រូវកាស    កាចខ្លាសមហិមា
គិតហើយក្សត្រា    ពុំចេញសូរសង ៗ    ក្បិណណោះវិឡា
យល់ហើយក្រោធា    ពេកពន់កន្ទង    ជាម្ដេចហ៊ានអួត

ប្រគួតផ្ទឹមផង  នឹងនាងទងវង  ស្រីសុវណ្ណា ។
មិនកោតមិនក្រែង  ហ៊ានមកក្លាយខ្លួន  មាត់បៀមបូផា
ស្មានគេមិនយល់  កិច្ចកល់មាយា  ឲ្យព្រះពជា
សព្វព្រះហឫទ័យ ។  ហើយស្ទុះទៅនាំ  បុប្ផានោះនាំ
ទៅទូលក្សត្រថ្លៃ  ថាខ្ញុំមានបុណ្យ  លើសលន់ពេកក្រៃ
បុប្ផាមាសមៃ  ជ្រុសចាកឧស្សា ។  សូមស្ដេចឧត្ដម
ទ្រង់ស្រឡាញ់ខ្ញុំ  គួរគាប់មហិមា  កំសត់ក្សត្រី
ស្រីសុវណ្ណា  នាងធ្វើបំប៉ា  ល្អលទើទៃ ។
ទូលហើយវិញ  សើចសងស៊ានថា  ឱអស្ចារ្យក្រៃ
បីដូចគុជ្ឈសា  ឱពាស្កឹមស្កៃ  ស្បែកគ្រាតក្រៃ
ហាក់ដូចគិរី ។  សម្បុរសោតខ្មៅ  ម្ដេចឡើយយកម្សៅ
លាយលាបឥន្ទ្រី  ថាអង្គឯងស  សឹងល្អសោភី
បង្អួតកាយី  ផ្ទឹមនឹងសីហា ។  ចង់បានយសស័ក្ដិ
ខ្ពង់ខ្ពស់អាណាក់  អនេក្ខសោះសា  ពុំគិតឯប្រាណ
នឹងមានភ័យ្យា  កើតក្ដិនិន្ទា  បំណោរបេរធ្លាយ ។
ឱអញខ្មាសគាង  ខ្មាសលើសអស់នាង  ពេកពន់អម្បាយ
កាច់ក្ដិមេបា  វង្សាតាំងឡាយ  ជ្រិតចិត្តរាយមាយ
ចង់លើកអាត្មា ។  កាលនោះព្រះបាទ  ជៃជេតនាថ
ស្ដេចស្ដាប់វិញ  ករុណាបើកព្រះសូរ  បន្ទូលត្រាស់ថា

ហៃមេរីឡា ក្រេវក្រោធខឹងថ្វី ៗ ចូរហងចេញទៅ
កុំបីហងនៅ ឡើយរីឡារ៉ី ពោលពាក្យទ្រគោះ
ឆ្លើយឈ្មោះឡើយនៃ មាតរឹងស្រដី ពុំកោតបេស្តា ៗ
ហើយត្រាស់មកខ្ញី នឹងនាងទេវី ប្រាំពីរអង្គា
តាប់ហើយនាងធ្វើ អំពើប្ចេះណា ព្ភពាក្យរីឡា
ផាក់ហើយប្តូនៅ ៗ គេក្តិអាស្រូវភាស របឹងគ្នានខ្នាស
គ្មានដឹងខុសត្រូវ កាប់គេក្តិអាគ្នា មោហាយោយៅ
ថ្វីមិនចេញទៅ ឆាប់ ៗ មុំមា ៗ នាងស្តាប់ព្រះបង
ក្រោធក្រៃកន្ទុង បណ្តាញដេរថា នាងកិតទាងខ្វាប
អំណាចបេស្តា ញ័រអស់អង្គា ស្ទូនស្ទុតស្មារតី ៗ
អៀនចិនស្រពាប់ ស្រពោនក្រញូវក្រាប អប្សអស់រស្មី
មើលមុខដូចខ្មោច អាសោចគេរចី ពុំហានស្រដី
រាជាសាសង ៗ ហើយថ្វាយបង្គំ លាក្សត្រឧត្តម
ដើរសើមិនត្រង់ កិតកៃមហិមា នេត្រាឡឹនឡង់
សើលុតជង្គង់ ដួលលើធរណី ៗ រឹងគិតរឹងខឹង
អួលអន់តានតឹង ដោយខ្មាសសេនីយ ក្តៅក្តាត់ដូចភ្លើង
ឆេះឡើងថ្មី ៗ ពលពេលអង្គស្រី ឈឺឈៀបឈួលផ្សា ៗ
ហើយខំដើរដល់ មន្ទីមន្ទល់ ក្រៀមក្រំក្រ្តា
រុះរើះជុំទុំ សុក្ខុភាសា ធ្វើម្តេចបានរា ខ្វាត់ខ្វាយចេញម្តង ៗ

ទើបនាងសុរិយា ក្រែកក្រាស់ថ្លែងថា ឥឡូវនេះម្ដង
បើដោយគំនិត អញគិតនេះហោង យល់ល្អគន្លង
តាមដោយបញ្ញា ៗ បើអស់នាងព្រម គិតយល់ថាល្មម
ដូចពាក្យអញថា នឹងឆាយអញគិត តាមចិត្តអញណា
នូវប្រើប្រាជ្ញា អាអធិប្បាយ ៗ យើងផ្ញើអក្ខរ
ទៅព្រះបិតា អស់នាងឯនាយ ឲ្យមកលល្ងង
ល្បួងស្ដេចទៅឆ្ងាយ សឹមយើងឯអាយ ធ្វើគល់កិច្ចការ ៗ
លុះនាងសម្រាល កូនស្នងត្រកាល មកវេលាណា
យើងឲ្យធ្លាក់ឈើ ធ្វើតាមកូនការ កូននោះសោតណា
យើងសម្លាប់បង់ ៗ នាងតាំងប្រាំមួយ បានដឹងដម្រួយ
អាឯងគ្រប់អង្គ ហេតុចិត្តលោភៅ មោហោឆោតបង់
ប្រមាថព្រះអង្គ ស្រីសុវណ្ណា ៗ ហើយនាងតាក់តែង
រិះគិតចាត់ចែង សរសេរអក្ខរ គ្រប់នាងស្រស់ស្រីល
ប្រាំពីរធិតា ចែងបេះមោហា កុហកកិច្ចកល់ ៗ
ខ្ញុំបុត្រពុំងា ក្រញក្រាបសិរសា សំពះមកដល់ ទ្រង់ជាបិតា
ថ្លៃថ្លានិមល ដ្បិតកូនតែងទុល ទុក្ខទោមនស្សា ៗ
ពីដូចចក្រី បានអង្គមហេសី ក្រោយនោះមកណា
ឲ្យខ្ញុំបំរើ សារពើហើយការ ដេពោលផ្ដាស្បា
តែរៀងរាល់ថ្ងៃ ៗ ឥឡូវខុសខាន កូនស្នងកល្យាណា

កើតទុក្ខខ្លាំងក្រៃ ស្តេចឥតសប្បុរស ពុំយល់បុត្រថ្លៃ
ខ្ចាសអស់សេនី នឹងរាស្ត្រទាំងឡាយ ៗ ហើយប្រជុំគ្នា
ប្រាំពីរអគ្គា មកហើយនិយាយ គិតគួរជំនុំ
សុំក្ខកិប្រាយ មិនហ៊ានថែងជាយ ឲ្យលេចឡើយនៃ ៗ
ថែថមពុំកក្រទ្ត ពរឹងចង់បាន ស្តេចស្តែងឃ្លាឃ្លៃ
គុនគិតឆ្ងាយឆ្ងល់ សោកសស់ក្រៃក្រៃ នឹងទូលស្តេចនៃ
ឲ្យស្តេចយាត្រា ៗ ខ្ទះឆ្ងើយថាអើ កាលមុនមិញតើ
អញឮគេថា មែនមានដំរី កុងព្រៃព្រឹក្សា
ច្រើនពន់មហិមា ល្អ ៗ ប្រពៃ ៗ យើងទូលបង្គំ
ឲ្យស្តេចប្រពាធ អទ្ធាព្រឹក្សព្រៃ ទៅតាមទាក់ដំ
រីគុំផ្ទួននៃ យល់ដាង៉ាយក្រៃ ក្រអ៊ូឡើយណា ៗ
ប្រាំពីរសេដ្ឋី បានឃើញសេចក្តី ស្រាក់ស្រានចិន្តា
ស្រេចហើយផ្តុំផ្តំ កិច្ចកម្មវាចា ប្រើមេទាសា
ទៅទូលក្សត្រ ៗ កុំឲ្យកូនគិត ថែថប់ព្រួយចិត្ត
សោកសល់សែនថ្វី នឹងកើតពេគ្គា ផ្តន្ទាយាយើ
ដម្កាត់ព្រាជី បៀតបៀនអាត្មា ៗ អញនឹងចូលទៅ
ក្រាបទូលព្រះទៅ ឲ្យស្តេចយាត្រា កុំឲ្យសង្ស័
ព្រះទ័យធីតា អញនឹងធានា ឲ្យបានដូចបន់ ៗ
ពាសីលុតលា វិលវិងយាត្រា ដល់ដូចបំណង

ទូលនាងទេវី បុត្រនោះហោង អស់ពាក្យពេជន៍ផង
តាមព្រះបិតា ៗ ប្រាំពីរក្សត្រី ត្រេកអរពេកក្រៃ
ស្រាកស្រានទ័យ្យា ល្ហៃល្ហើយស្រយាល ត្រអាលត្រប់គ្នា
ប្រាំពីរអង្គា រុះរាយសាសន៍ '' ឯអង្គសេដ្ឋី
ក្រោយមេទាសី វិលទៅហើយហោង ប្រដាប់អាត្មា
មីមាចរង្គ រួតរះដោយដង ចូលក្នុងសេម្មា ៗ
ហើយឡើងទៅទូល ព្រះបាទឥស្សូរ ធម្មិករាជា
បពិត្រព្រះបាទ ននាថថ្លៃថ្លា ដ្បិតមានគុណធ្ងួសា
សរសើប្រពៃ ៗ ទាំងឈ្មោលទាំងញី រួសហានទាំងពីរ
ធាំស្កុមស្កៃ ហើយមានបរិពា ផាសផាប្រញាយ
ទើបប្រញាប់ថ្វាយ ដំណឹងនេះណា ៗ ធម្មិកភូមី
លុះឮសេដ្ឋី ទូលទើបក្សត្រា ទ្រង់ព្រះអំណរ
ឯងអរមហិមា ស្ដេចឲ្យសេនា អញ្ជើញបុត្រថ្លៃ ៗ
មកដល់ហើយហោង ទើបក្សត្រប្រះប្រន ត្រេកត្រាស់ថាហៃ
បាបុត្តពន្ធក មុះមកដល់អៃ ឥឡូវនេះនៃ
សេដ្ឋីទូលថា ៗ មានស្ដេចដំរី សរដូចសំឡី
ទាំងគូទោរណា និតនៅក្នុងព្រៃ ល្អក្រៃសោភា
អញ្ចូចន៍ប្រើបា តាមទាក់ឲ្យបាន ៗ បើដូចបំណង
ចិត្តយើងប៉ុនប៉ង ហេតុបុណ្យយើងមាន ទុកជាមង្គល

សុគលក្រេមគក្រាន កើតកេរ្តិ៍ថ្កើងថ្កាន ដ្បិតព្រះបារមី ។
បើពជនត្តោ វិសេះសេដ្ឋោ សម្រាលបេ្តី
វីពជគុជ្ឈសា ទេ្វហាសោកី បំរើនព្រះស្រី
ពជាទិសព្រ ។ ឯព្រះពជបុត្ត ទិនអគ្គលំអុត
ក្រាបក្រោមបាទា ទឹកនឹងបង់ខាន ពុំហ៊ានឡើយណា
ទទួលអាជ្ញា ទៅតាមបង្គាប់ ។ ហើយស្ដេចលុតលា
ព្រះវរបិតា វិលវឹងត្រឡប់ ដល់ប្អូនបណ្ដូល
បន្ទូលប្រាយប្រាប់ អស់អាថិសាសព្ទ ពីព្រះបិតា ។
ប្អូនអើយឥឡូវ សម្ដេចលួងប៊ូវ មានព្រះឱង្ការ
ឲ្យបងចេញទៅ តាមទាក់គុជ្ឈសា សសុតសោភា
ទាំងឈ្មោលទាំងញី ។ បងនឹងទូលទាស់ ខ្លាចក្រែងមានខុស
ដម្រាស់ចក្រី ហាក់បងពុំហ៊ាន បែកពីមហេសី
នឹងទៅក្រែងស្រី នាងនៅលំបាក ។ បងគិតគក់ថ្ងៃ
សឹងចាស់ខែថ្ងៃ ចេញចោលវរលក្ស ហាក់បងដោះដៃ
ពាំស្វាមីភក្ត្រ ខានខ្លាចចោមចក្រ អាក់អន់ព្រះទ័យ
ស្ដែងស្ដេចគិតគ្រប់ ព្រះទ័យធុញថប់ ហើយប្រាប់សេណី
ឲ្យរៀបរេហ៍ពល ប្រញាប់ឃ្លាតខ្ចី ទៅទាក់ដំរី
គ្រាតឡូវណា ។ កញ្ញាព្រះចោមចៅ ព្រះឱស្ឋហាហៅ
ប្រាំពីរជិត ថាហៃប្អូនស្រី ចូលមកអ.យព

ស្តាប់បងបរិហា ថាថ្ងៃប្រាប់មេ ៗ ប្អូនអើយនាងនៅ
បងលាប្អូនទៅ ព្រៃព្រឹក្សទួរ ប្អូននៅឯក្រោយ
កុំស្ដាយណាមេ កុំគិតបែកបែរ ប្រែចិត្តឫស្យា ៗ
បើបងទៅបាត់ ហើយកើតដំកាត់ ព្យាធិរោគា
កុំមើលបំណាំ ចូលចាំរក្សា ខុសគាប់គាបជា
អត់ធុនត្រង់រង់ ៗ បើសុវណ្ណា ប្រែសូត្របុត្រា
ក្រឆាយក្ដីហោង បងសោតសូមផ្ញើ ប្អូនលើនាងផង
ពីកក្រសួនត្រង អស់អង្គរក្សា ៗ ទោះបីទាសី
សុំស្និតនូវស្រី ស្រីឆ្គាក្ដីណា គោងព្រះរាជទាន
ធនធានជា ៗ ឲ្យនៅរក្សា ព្រះរាជទេវី ៗ
ប្រាំពីរអង្គា ស្ដាប់ព្រះឱង្ក ត្រេកអរពេកក្រៃ
ពើបលើគំនិត នាងគិតស្រាប់ខ្ញី កាបកាលកំណើ
ប៉ងទឹងផ្ដា ៗ គិតថានេះម្ដង លុះនៅបំណាង
ចិត្តយើងប្រាថ្នា មិនរួចពីដៃ ក្សិណាក្សៃដន្ទា
ប្រាកដកាលគ្រា ឥឡូវនេះម្ដង កាលណោះព្រះបាទ
ព្រះបរមនាថ នាំនាងទងវង់ ឡើងថ្វាយបង្គំ
មាតាបព្វះបព្វង ក្រញ្ញក្រាបរាប់រង ប្រញ្ញប្រាណប្រណិបត្តិ ៗ
ក្សិណនាងសច្ចា ជាព្រះមាតា យង់យល់បុត្ររត្ន
ស្រួសរាយទទួល អរអញ្ជើញថ្វាត់ គង់ព្រមមហាក្សត្រិយ

ទាំងបីអគ្គា ៗ ហើយនាំនាងថ្លៃ ទ្រង់ព្រះក្រាបក្រែ
នាងសាបង្កា ត្រាស់បន្ទូលដេ ថាមេះនេះណា
ធ្វើមិនគួរការ នាំឲ្យបំភាន់ ៗ អញគ្មានកូនចៅ
ដូរជាតិកំឡៅ ដូចវាសាមាន ធ្វើកលមាយា
បៀមផ្កាហើយហាន ចរចើនមកប្តាន ឥតខ្លាសមហិមា
ចូរចុះចេញទៅ តែនាងស្រីពៅ កែវសុវណ្ណា
នេះនៃជាបុត្រ ពិសុទ្ធស្នេហា អ្នកឡើយអស់ណា
បើកបង់ស្មើផង ៗ ក្បិនណោះផយា សំណោះសូសា
រាជបុត្រស្នេស្នង មាសមកនេះណា ប្រាថ្នាប៉ុនប៉ង
ប្រការម្តេចហោង ប្រាយប្រាប់ម្តាយរា ៗ រាជបុត្រវរវង្ស
លើកករកំបង់ បាទបទទូលថា ដ្បិតព្រះកូនរ
ព្រះវរបិតា ប្រើខ្ញុំយាត្រា ទៅទាក់ដំរី ៗ
ខ្ញុំមកនេះណា ថ្វាយបង្គំលា ព្រះវរជននី
សូមផ្ញើនាងនាង សង្វាពិសី នឹងលួងផូលី
សូមទ្រង់មេត្តា ៗ ដ្បិតគតិទៀនទេ បបួបានទេ
១០ ហើយនេះណា សំនឹងប្រសូតិ បុត្ររត្នថ្លៃថ្លា
ក្រោយខ្ញុំករុណា មិនលង់ឡើយហោង ៗ ហេតុនេះគឺខ្ញុំ
គួបកើតទុក្ខធំ ធំក្រៃកន្លង អាសូរស្រីពៅ
ឥតញាតិផៅពង្ស មានតែអ្នកផង នគរដទៃ ៗ

ព្រះវរមាតា ស្ដាប់បុត្រទូលលា វែងអាណិតក្រៃ
បើកបន្ទូលថា ឱបុត្រថ្មើមថ្លៃ អ្នកកុំព្រួយអ្វី
ម្ដាយជានារី ៗ បើនាងឈឺផ្ទៃ ទោះយប់ទោះថ្ងៃ
ក្រោយស្ងួនស្នែស្នង មានពេទ្យមេមុត ឆាប់ឆុតកន្ទង
មុកមន្ត្រីផង ហោមបាំរក្សា ៗ ហើយត្រាស់ត្រអាល
ទឹងនាងត្រកាល ស្រីសុវណ្ណា ស្ងួនអើយកុំគិត
ព្រួយក្នុងចិន្ដា នូវទឹងមាតា កុំបារម្ភអ្វី ៗ
ទោះក្រទោះងាយ កិច្ចការសម្ងាយ សុខទុក្ខផងក្ដី
ម្ដាយមិនឲ្យឆ្គង មោះហ្មងចិត្តស្រី ម្ដាយវែងប្រណី
កូនកែវកំព្រា ៗ នាងស្ដាប់ព្រះបន់ ទូលទើបស្រីតន់
កាយករទ្ម ដឿជាក់ក្នុងពោះ ស្ងើស្ងោះដម្ង
មិនមានសង្កា រង្គៀសថ្នាំងថ្នាក់ ៗ កាលនោះកូមី
លាព្រះដីនី នាំនាងវរលក្ខ ស្ដេចវិលវិញឋាន
ទៅស្ថានដំណាក់ សោយសោកឥតអាក់ ដោយពុំចង់ឃ្លាត ៗ
ប្រកៀកត្រួតរត ថ្នាក់ថ្នមផ្ដេកផ្ដិត ថៃថើបនាងនាថ
លួងលោមថាឱ ថ្មើមថ្លៃមានជាត បងពុំចង់ឃ្លាត
បែកពីកក្ដ្រា ៗ ឱបងបែកទៅ ក្នុងពោះអួលក្ដៅ
ក្ដៅអស់អង្គា រំជួលចិត្តថ្មើម ដង្ហើមទេយ្យា
ឈឺទៀបឈ្លួលផ្សា ទ្រូងតឹងស្មើធ្លាយ ៗ ស្ងួនអើយហេតុកម្ម

វេពចង់ចាំ　　តាមពីព្រេងនាយ　　ឯងអាចឲ្យខាត់
ប្រាស់ព្រាត់ចេញឆ្ងាយ　　ប្អូននៅឯអាយ　　កុំប្រែហែសការ ៗ
ក្សិនក្សត្រីថ្លៃ　　នាងដោះយកស្បៃ　　នូវស្នៀតកេសា
ថ្វាយទៅព្រះបាទ　　នទាថសោកា　　តាំងតួរដេយ្យា
សោះនឹងអាឡៃ ៗ　　ម្ចាស់សើយប្អូននៅ　　ទ្រព្យប្អូនថ្វាយទៅ
តាមហែក្សត្រថ្លៃ　　ទុកតាងខ្លួនខ្ញុំ　　ពិតពុំសង្ស័យ
ទ្រព្យនេះដែលដៃ　　ដិតដោយព្រះអង្គ ៗ　　ព្រះរៀមក្សត្រា
ស្តាប់ហើយរាជា　　ក្សិកក្សួលយំផង　　ស្តេចយកព្រះពស
ស្រឹលស្រស់ឥតហ្មង　　ប្រទានស្នូនគ្រង　　ស្នងអង្គក្សត្រថ្លៃ ៗ
ហើយបន្ទូលថា　　ឱកែវដីពី　　បងឃ្លាតទីទៃ
នាងនៅឯក្រោយ　　កំភ្លាយឡើយនៃ　　ដ្បិតមាសថ្មើមថ្លៃ
ឯកឥតសន្តាន ៗ　　ទុំព្រំអញបង　　ត្រឡប់វិលផ្គង
មកមូលរួមស្ថាន　　កុំសួនពិសេស　　ប្រែហែសខ្លួនប្រាន
ទុកចិត្តម្តេចបាន　　គេសិងបុស្សា ៗ　　កាលនោះក្សត្រី
ប្រសើរស្រស់ស្រី　　ព្រះទ័យខ្លោចផ្សា　　កិលាបប្រាសប្រាន
ទូលទូតមហិមា　　ក្តៅក្តួលទេយ្យា　　បន្ទូលថ្លែងថា ៗ
ឱះឱព្រះបង　　ឥឡូវនេះម្តង　　ទ្រង់ទឹងឃ្លាតឃ្លា
ចាកចម្ងៀងបង់　　លុនលង់គ្នាត់ណា　　អាចឲ្យប្អូនភ្នា
ទុកទន្ទឹងនៅ ៗ　　ប្អូនព្រាត់ពីស្រុក　　ទាំងព្រះជិនទុក

ដីទីទោមទៅ ឥតញាតិពង្សា សុតតែអ្នកក្រៅ
នគរលំនៅ ឆ្ងាយក្រៃមហិមា មកបានសម្បត្តិ
សំបូររឹត បិតុណាព្រងា ប្អូនស្មានសុខសល់
ដូចកលប្រាថ្នា ម្ដេចឡើយវិជា ទុក្ខទៀតនេះម្ដង ៗ
បើស្ដេចទៅបាត់ៗ ហើយវង់ស្ងាត់ៗ ហើយប្អូនវង់ៗ
ទុកមើលផ្លូវៗ ព្រះបាទបង់ៗ អើយខ្ញុំវង់
ផ្ដេចផ្ដួនា ៗ ឱះឱម្ចាស់ខ្ញុំៗ វិង់ក្រៀមក្រំៗ
ក្រៃក្ដាត់ណា ពីតូចខ្ញុំបាន រួមស្ងានស្នេហា
ពិតពុំដែលជា មន្ទិលគ្នាគ្គង់ ៗ អម្ចាស់ពិសេស
ស្ដេចកុំប្រហែស ព្រៃព្រឹក្សប្រែលង់ អង្គាស្រងាត់
សឹងសត្វយុងយូង រមាសខ្លាផង សាហាវហឹងសា
ទោះទាក់ជំរី សាសរនោះក្ដី ប្រយត្នអាត្មា
កុំស្ដេចឆោតធុត លោលុកពះពា ពានពើបទឹងវា
វាកំឆតដៃ ៗ ព្រះស្ដើយប្អូនវែង តានតឹងចម្បង
បិត្តបែកពីរបី ជប់មួយនោះមិញ គតិពេញក្នុងផ្ទៃ
ជប់មួយក្សត្រថ្ងៃ ត្រេចផោយអង្គា ៗ ជ័យជេដ្ឋក្សត្រថ្ងៃ
បន្ទូលថាពៃ ឱកែវជីវ៉ា កុំព្រួយព្រះទ័យ
ត្រង់បង់នេះណា ចូរស្ងួនរក្សា គតិឲ្យបានល្អ ៗ
ស្ដេចផ្ដាំទេវី ស្រេចព្រះភូមី ទ្រង់ត្រឡឹងបវរ

ប្រដាប់ព្រះអង្គ ហើយទ្រង់ចាកចរ ទៅប្រាងកុម្ភរ
បិតាក្សត្រក្សត្រ ៗ ថ្វាយបង្គំលា ព្រះវរបិតា
ឥស្សរប្រធាន បាទបបក្រួញក្រាប ទន្ទាបប្រួញប្រាណ
សូមពរក្សត្រក្សត្រ ស្តែងស្តេចយាត្រា ៗ កាលនោះព្រះវរ
បិតាភូធរ យល់ឱរសា ស្តេចបើកព្រះសូ
បន្ទូលត្រាស់ថា ហៃស្ងួនពុំង៉ារ សម្លាញ់ឪពុក ៗ
បាទៅនេះម្តង សូមឲ្យបុណ្យផង ជួយជូនដាក់ទុក
និរាសចាកភ័យ សូមបានសាន្តសុខ វិលមកយល់មុខ
អង្គអញបិតា ៗ មួយទោះសត្រូវ អាសោយោយៅ
ប្រមាទពាធា ឲ្យចាញ់បាក់បប់ ប្រានប្របរួញព
ខ្ជបខ្ជាបចេស្តា តបៈបារមី ៗ ដៃដេតភូធរ
ទទួលព្រះពរ បិតាបក្រី ហើយស្តេចវន្ទា
លុតលាវឹងខ្ជី ឡើងគង់ដំរី បចាកសេម្ខា ៗ
រីព្រះភិលៀង ហៃហាមរៀបរៀង នៅអស់សេនា
ពលពាលសន្ធឹក រើកត្រៀបត្រា ក្មេងសព្វកាសា
ដេញដំរីពង្ស ៗ ចូលដល់ព្រឹក្សព្រៃ ត្រឈឹងត្រឈៃ
លូតលាស់បំព្រង ខ្ចុះក្តិបខ្ចុះចាស់ ស្រគាលទុំផង
សេនាគិកកង រើសធីគ្រប់គ្នា ៗ ស្តេចទតយល់ភ្នំ
ចិញ្ចង់ធាធំ សោតសឹងសីលា

មើលជ្រោយមើលជ្រោះ បន្ទោះបុព្វតា ខ្ពង់ខ្ពស់មហិមា
ស្កឹមស្កៃយល់ឆ្ងាយ ៗ ស្ដេចផ្អកព្រះទ័យ ថាឱមាសថ្លៃ
បងបង់មកឆ្ងាយ ប្អូននៅម្នាក់ឯង ចម្បែងកង្កាយ
សំមាសពន្លាយ ទ្រូញទល់ទ្រូកា ៗ ស្ងួននើយហើយបង
បានស្ងួនមកផង នៃបងនឹងរៀមរ៉ា បងនឹងនាំនាង
យាសយានយាត្រា ទតអស់អង្វា ព្រៃព្រឹក្សទ្រួលទី ៗ
ស្ងួននើយអម្រឹត គៀងគូគរគឹក បណ្ដើរឈ្មោលញី
ដូចបងនឹងប្អូន ស្រីស្ងួនពីសី វែងរួមមេត្រី
សំណេះទឹងគ្នា ៗ មាសសើយបក្សី បក្សាផងក្ដី
ទំទៀបគូវា សូរស័ព្ទសុះស្មៀវ ទ្វាខៀវបរបារ
ហាក់មាត់ស្ងួនក្វា ស៊ានសើចទឹងបង ៗ បងរងស្រណោះ
អាឡៃអាឡោះ ស្រីស្រស់ឥតធ្គង ស្រមើស្រមៃ
មៃ ៗ ក្ដាត់ហោង ផ្ញើម្ដេចឡើយបង បានយល់មុខមេ ៗ
ស្ដេចថាឱស្បៃ ទិព្វទើបកាស័យ ពីប្អូនមាសស្នេ
នៅស្មៀតកេសី ប្អូនស្រីផ្ដាំផ្ដៃ ទុកតាងខ្លួនមេ
សោះបងអាឡៃ ៗ ពិដោរឈ្ងុយឈ្ងប់ ក្លិនក្លែបត្រឡប់
ជាប់នៅនឹងស្បៃ បងរិះបងរឹង តានតឹងចិត្តក្រៃ
ក្រៀមក្រំហឫទ័យ សង្វេគអនិច្ចា ៗ ស្ដេចចូលបតស្មោះ
ហើយត្រាស់ឲ្យបោះ សន្ទុងពង់ញ៉ា ព្រះគ្រូញ៉ុំថៅ

ហ្ម៉ីក្រោយក្ដាត់ណា ប្រដាប់អាត្មា ដោយទូទៃ

ឡើសរកផ្អាក់ ផ្ទាប់ហ្វឹកហ្វឺនទាក់ បានបទនោះនៃ

ទឹងទលឿនលន់ ដោះកុនស្រវៃ មិនដាលដោយភ័យ

មិនភ្ញឹករអា ៗ មិនរាថយដៃ ស្ទុះស្ទួយកជ័យ

ក្លាហានមហិមា . ទោះតាំងទ្រមាក់ ស៊ូបញ្ឈាក់រា

រើសអ្នកក្លៀវក្លា ដាន់លើអែបឈៀង ៗ

ប្រាប់ស្រេចទ្រមាក់ ទន់ទាញខ្សែផ្អាក់ ដាក់បង់រយោង

លើខ្នងគុជ្ឈសា ត្រៀបត្រារៀបរាង

ដាដួរសន្ធាង ប្រញាប់ម្មីមា ៗ ហើយផ្ទុកប្រគាំ

បរបេញទន្ទុំ មុខក្រោយតាមគ្នា កាលណោះព្រះបាទ

ននាងថ្ងៃថ្ងា ឡើងគង់គុជ្ឈា សាសឹងធំក្រៃ . ៗ

បើកបរចេញថ្កាន លះលែងបាកស្ថាន ព្រះពន្លាដៃ

ស្ដែងស្ដេបតត្រុក រានរុក្ខក្ខព្រៃ ពុំបានអាស្រៃ

ឈរឈប់ឡើយហោង ៗ ទន្ទ្រានកាប់ឆ្កា ស្បូវស្ប្រាតបន្ទា

ញៀតញឹកកន្ទង លុងលុះពើបពះ ប្រទះទាំងហ្វូង

ច្រើនក្រៃក្ដាត់ហោង ពាសពេញអត្វា ៗ ស្រែករពាទ្រហឹង

ស្បូវសត្វអ៊ីងអឹង ស្មើផ្កាយកស្យធា ឆាយឈុះទ្រលោម

លេងក្រោមព្រឹក្សា ធុមខ្ទិនមនុស្សា ផ្ទួលដើមត្រសង ។

ស្រៀវស្រែកសន្ធប់ ខ្ទរខ្ទាររញ័ររញាប់ ព្រញព្រឺអស់អង្គ

ឯដំរីផ្ទាត់ ទ្រមាក់សឹងផ្ទង់ ចរចូលដម្រង់ ប្រយ័ត្នគ្រប់គ្នា
លុះដល់កលិយុគ ចូលដេញសម្រុក តើបពានហ្វូងវា
ពិតពុំផ្អើលផ្អូក ភ្ញឹកភ្ញូកហើយវា ទុពទុលផុលគ្នា
គៀកកិតក្ដាត់ហោង ៗ គេចគៀងប្រែប្រាណ តបះហៅហាន
ស្វិតស្វាញកន្ទង ល្អិតល្អោចព្រៃព្រឹក្ស ស្ងោកស្ងឹកនោះផង
រុះរោយជាមួយ បែកបាក់រុក្ខា ៗ ក្បែរណាផ្ទាក់មានជ័យ
ដាលដេញហ្វូងព្រៃ ចាលចាញ់រុញរក រួតរត់ដាលដោះ
ផ្ទុកផ្ទោះតក្កមា សម្ប់ស្បែងវេអា ហោលបាត់ពុំយល់ ៗ
ក្ដួនហ្វូងខ្ចាត់ខ្ចាយ ហោលបែកព្រាត់ព្រាយ គិតកែរចល់
ផ្ទាក់រឹងក្លៀវក្លា បំពាដេញដល់ ទ្រមាក់អស់សល់
ចាប់ចោលប្រកាំ ៗ ខុះទេពុំត្រូវ ខេខឹងក្រញូវ
ចូលជិតលលា ប្រុងប្រាណអាត្មា ហត្ថាទន្ទាំ
បានបោះប្រកាំ ត្រូវត្រង់បាទា ៗ ចុះចងដោយគល់
ឈើឈរវង់ល់ រងើកគៀបគ្រា គ្នាខ្វះដេញញែក
ចូលដែកហ្វូងវា រកពជគុជ្ជសា សរសុទ្ធពុំយល់ ៗ
រុកពនសព្វព្រៃ ព្រួយប្រាណទីទៃ សង្វាតខ្វាយខ្វល់
តត្រែតសៀតសឹក ដោយប្រែកផ្ទាក់ផ្ទុល់ អស់ចិត្តពុំយល់
ធុញថប់គំនិត ៗ ហើយមកក្រាបទូល ព្រះបាទឥស្សរ
ធិរាជរីករិត ស្ដេចទ្រង់ក្រេវក្រោធ គិរោធខ្ញាំងក្ដាត់

វិលវិញមកស្ថិត នៅព្រះបន្ទា ៗ . ស្ដេចត្រាស់ឲ្យហៅ
ភ្នាក់ងារម៉ត្រៅ មកហើយក្សត្រា បន្ទូលទ្រគោះ
កម្រោះត្រាស់ថា ហៃអស់ភ្នាក់ងារ ម៉ហៅនេះម្ដង ៗ
ដើមឡើយសេដ្ឋី ទៅទូលក្សត្រថ្ងៃ ព្រះជិនុកប្បាស់ច្បង
ជាមានសំបុត្រ ប្រាកដជាម្ដង ពីនាយម៉ផង
ឲ្យទូលក្សត្រា ៗ ជាមានដំរី សរដូចសំឡី
ទាំងគូនោះណា ទើបព្រះជម្រាស់ ត្រាស់លើសិរសា
ឲ្យអញយាត្រា តាមទាក់ឲ្យបាន ៗ លុះដល់អញមក
អញរុកពនរក ត្រឡប់ជាគ្មាន មិនហ៊ានបំពោត
បញ្ឆោតអញបាន មិនស្ដាប់មិនទាន ពីព្រះអាជ្ញា ៗ
កាលនោះនាយម៉ ភៃភិតភ្ញៃកសរ ប្រណម្យទូលថា
បពិតព្រះបាទ ននាថថ្ងៃថ្លា យើងខ្ញុំគ្រប់គ្នា
ពុំដឹងឡើយហោង ៗ កាលឲ្យក្រាបទូល អម្ចាស់វង្សកូល
ជាមានហ្វូងផង ដំរីស រូបល្អកន្ទង
ខ្ញុំពុំឃើញផង សូមទ្រង់ករុណា ៗ កាលឲ្យសំបុត្រ
ចូលទៅប្រាកដ បានបោះទាំងត្រា វៃក្រែងខ្ញុំភកូត
បំពោតបេស្ដា ខ្ញុំនឹងធានា ថ្វាយជីបជនធន ៗ
ទោះទាំងញាតិផៅ ប្រពន្ធកូនចៅ ពូជពង្សខ្ញុំហោង
តាមតែក្សត្រថ្ងៃ ប្រពៃប្បាស់ច្បង ផ្ជើតគត់ក្ដីហោង

តាមទោសគាត្ង ។ ស្តេចស្តាប់ទំនួល ព្រះបាទឥសូរ
ពុំចេញបរហា ទ្រង់ជ្រាបសេចក្តី សព្វគ្រប់ប្រការ
ដោយព្រះប្រាជ្ញា ជវ័ទភនវៃ ។ ស្តេចព្រួយព្រះចិន
ជាដោយភូមិន្ទ សុទ្ធិសង្វៀ ទឹងនាងប្រាំពីរ
អគ្គីនោះនៃ ចិត្តបុស្យាក្រៃ ទ្រុស្តទ្រើសយុងឃ្នង ។
ស្តេចគន់គិតគ្រប់ ថប់ហើយរឹងថប់ ពុំចេញសូរសង
ឧសុវណ្ណា ពុំងារស្ងួបង ម្ងះហើយសំរង
ទុកតែងមើលផ្លូវ ។ លុះចូលរាត្រី សម្តេចចក្រី
អន់អួលក្តាត់ក្តៅ ស្តេចចូលផ្ទុំ សំងំនិតនៅ
លុងលុះលក់ទៅ តាំងទុក្ខឯកា ។ ព្រះបាទភូមិន្ទ
ទ្រង់ព្រះសុបិន ហាក់ព្រះពជា ស្តេចបានគុជ្ជន
នរេទថ្ងៃថ្ងា សារសុតសោកា ធាត់ធំស្កមស្កៃ ។
ហាក់ញ្ញាវ័ទ ល្អល្អះសោភ័ន សីហនាថថ្កើងក្រៃ
ស្តេចគង់គុជ្ជា យាត្រាដល់ញ្ញ ស្ពានស្នួគិប្រពៃ
យល់ព្រះចន្ទ្រា ។ ស្តេចឈរណោងចាប់ ព្រះចន្ទ្រាខ្ជាប់
ទាញជិតឧរា ត្រេកត្រិសមនោ សានសោមនស្សា
កាលនោះឧរា ចាប់ចន្ទចរចេញ ។ ស្តេចតាមពុំទាន់
ក្សិណទ្រង់រុសពន់ វិលវិងមកវិញ ពុំយល់គុជ្ជា
ក្សត្រារង់ម្ចិញ ព្រះទ័យស្រទាញ់ អាឡូយនឹកស្តាយ ។

ហើយស្ដេចចុះថ្កាន ចាកស្ថិតិវិមាន ដើរតែដោយកាយ
ទុះទិសាណាត រឹងគិតគ្មានណាយ ម្ដេចឡើយនឹងព្រាយ
ព្រាត់ចេញទៀតទៅ ៗ យើងទឹងឈប់ស្មុះ ជ័យដេតត្រឹមនេះ
ថ្ងៃពីនាងទៅ សុវណ្ណបុប្ផា ក្រោយព្រះចាមទៅ
ដែលស្ដេចចេញទៅ ទាក់ដំរីសា ៗ នាងតែងទៅគាល់
ពីព្រះទ្រង់ធម៌ បិតាមាតា ពុំដែលខកខាន
មួយទេវណា ស្ដេចតែងបរបា សម្នេះស្នេស្នង ៗ
ពីព្រះរាជា ទ្រង់ព្រះករុណា រួមរក្សស្ងួនគ្រង
មិនឲ្យអាក់អន់ ស្រពន់ចិត្តហោង ស្រឡាញ់ឥតហ្មង
មន្ទិលសង្កា ៗ ស្ដេចត្រាស់ត្រអាល សម្រួលក្រសាល
ហៃកែវសុវណ្ណា រីគកិស្រីថ្ងៃ ចាស់គ្រប់មាសា
កុំគាល់បិតា នឿយណាស់ស្រីថ្ងៃ ៗ មួយខែក្រង់សម្រាល
ព្រះរាជកុមារ ទោះយប់ទោះថ្ងៃ កូនឲ្យមកប្រាប់
យើងឆាប់វៃ ៗ កុំមាសមិត្តថ្ងៃ ទុកចិត្តភស់ក ៗ
ម្ដាយនឹងទៅឯង ថែរទាំគាក់តែង មើលមាសពំនារ
នឹងបោលម្ដេចមេ ឲ្យគេរក្សា ចិត្តម្ដាយសង្កា
សន្ទិះសង្ស័យ ៗ នាងស្ដាប់ភូមី នៅព្រះជីទី
បន្ទូលប្ដោះនៃ ហើយនាងក្រាបលា យាត្រាវិលវៃ
បបុះមកញ ប្រសាទសោភា នាងនៅសព្វថ្ងៃ

ព្រួយព្រះទ័យក្រៃ ខ្វាចគេផ្ដន្ទា នាងសោកសង្រេង
ចម្រើនចិន្ដា គិតព្រះជេដ្ឋា តម្កើងស្វាមី ៗ
ហើយនាងផ្គុតផ្គង់ មារយាតជម្រង់ ចងចាំស្វារតី
ផ្ដេកផ្ដិតស្និតស្នាល ស្រិង្គាទាសី នូវអស់ទាំងស្រី
ព្រះស្នំផងណា ៗ ទោះទាំងក្សត្រី ប្រាំពីរនោះក្ដី
សិងស្និតស្នេហា មិនឲ្យអន់អាក់ ថ្នាំងថ្នាក់ចិន្ដា
ផ្សិតនាងកំព្រា ឯកាគន្ធ ៗ ប្រយោជន៍នឹងផ្ញើ
ព្រះអគ្គឯងលើ អស់នាងនោះហោង កុំឲ្យគេធ្វើ
បាបកម្មដល់អគ្គ រួមរក់ស្ងួនគ្រង សព្វទិនទៅ ៗ
ឯអគ្គក្សត្រី ប្រាំពីរនោះក្ដី ហាក់មានស្នេហា
ដាក់ខ្លួនស្រឡូត វែងស្លូតពិតណា ដោយនូវប្រាជ្ញា
លួងលោមអម្បាយ ៗ បំរើផ្គាប់ផ្គុន នាងនាថស្រីគន់
អស់គញខ្វល់ខ្វាយ រីឯពង់ពោះ ពុំស្មោះស្រែស្រាយ
ហេតុចិត្តគិតឆ្ងាយ លោបលន់ក្ដាត់ណា ៗ ពុំគិតវេរី
បុណ្យបាបអប្រិ ដូចដល់អាត្មា គិតតែប្រមាទ
នាងនាថសោភា ឲ្យក្សែជន្មា ដូចចិត្តប៉ុនប៉ង ៗ
មានមួយរាត្រី ព្រះអគ្គមហេសី អគ្គឯកប្រាស់ប្រេន
គភិនាងទៀងទេ ១០ ខែហើយហោង ឈឺផ្ទៃកន្ទួង
ញ័រអស់អគ្គា ៗ ស្រីរតបវរ ព្រះទិស្វស្មោះស

លួងលោមចរចា ហៃមាសស្រស់ស្រិល ប្រាំពីរអគ្គ
ប្អូនអើយបងមហា ឈឺឈៀបឈ្លួលក្រៃ ៗ នាងទៅអញ្ជើញ
ព្រះបិតាយើង នូវមាតាថ្លៃ អញ្ជើញព្រះអគ្គ
កុំលុនឡើយនៃ ផ្សិតបងឈឺផ្ទៃ ប្រសូតបុត្រក្លា ៗ
កាលនោះនាងសត្វ ឯកាស្តេចស្តាប់ សារសងទូលថា
កុំព្រួយព្រះទ័យ ណាថ្លៃជីវា យើងខ្ញុំគ្រប់គ្នា
នៅនេះហើយនៃ ៗ បើនាក់ឈឺធ្ងន់ គួរគាប់ពេកពន់
អស់យើងទីទៃ ស្ងួនគ្រងពីភក្តិ រក្សាមាសថ្លៃ
គាងព្រះនេតនៃ ព្រះវរមាតា ៗ នាងធ្វើឧបាយ
សារសងដោះស្រាយ ហាក់មានមេតា អណោចអធម្ម
ៈគ្រៀមក្រមកក្រ្តា ឲ្យអស់ទាសា ទាសីផងយល់ ៗ
ឯអស់ស្នំស្និត ភ័យភាំងពេក្តាត់ មូលមករចប់
ពោឡាអឹងកង នាគន្ទមណ្ឌល រក្សានិមល
សម្តេចមហេសី ៗ ឯអគ្គធីតា ប្រាំពីរពិធារ
ណានូវសេចក្តី ថាអស់ស្រីស្នំ ព្រះក្រមទាសី
មូលមកកក្តី ដូច្នេះឯងណា ៗ យើងគិតយល់ក្រ
មិនដឹងបើរក កល់ធ្វើម្តេចម្តា បើយើងឲ្យចេញ
ទៅវិញយល់ផា ឆ្ងាយឥតសង្កា ចំនើង យើងធ្វើ ៗ
គិតសព្វសេចក្តី ហើយហៅទាសី ស្នំស្និតមកប្រើ

ថានាងពល់គ្នា　　នៅឥតអំពើ　　មើលមុខប្នះគេ
ធ្វើម្ដេចទឹងជា ៗ　　បើមេឈឺផ្អាល　　ទឹងនាងត្រកាល
អញនៅរក្សា　　ចូលអស់មេចេញ　　ក្រៅវិញស្រក
រៀបរកបណ្ដា　　ការផងទាំងឡាយ ៗ　　រកពេទ្យរកថ្នាំ
រកឆ្មបមកចាំ　　បែកផ្ទៃគ្រប់កាយ　　ឯអស់ទាសា
ម្នីម្នាប្រញាយ　　រូតរត់ព្រានព្រាយ　　ទិទៃគ្រប់គ្នា ៗ
នៅតែនាងស្រី　　ប្រាំពីរតិរថី　　ចាំវេជាយា
ឥតអ្នកណាមួយ　　មកជួយរក្សា　　មានតែវិទ្យា
នែបទឹងក្សត្រី ៗ　　យល់អង្គឹកល់　　ដឹងដោយយោបល់
គិតថាឱស្រី　　ប្រាំពីនេះរា　　រមោហាអប្រី
បំបែកទាសី　　ឲ្យចេញឆ្ងាយ ៗ　　សំរាកនៅធ្វើ
កិច្ចកលអំពើ　　នៃនាងឆោមឆាយ　　ហើយរកសម្លាប់
អញស្លាប់អន្តរាយ　　ទាំងបុត្រឆោមឆាយ　　អាសាសូន្យហោង ៗ
បើខ្លោះគួរអញ　　ដើរដោះដៃចេញ　　ឲ្យរួចរម្ងន
លបមើលបំណាំ　　កិច្ចកម្មនោះផង　　បើព្រះច្បះច្បង
ស្ដែងស្ដេចមកដល់ ៗ　　ហើយអញក្រាបទូល　　ព្រះបាទឥស្សូរ
ដោយក្នែកអញយល់　　ទូវនេះទឹងស្លាប់　　បាត់សព្វសូន្យសល់
តុំបានដឹងដល់　　ព្រះរៀមពកជា ៗ　　អញទឹងគបស្នង
គុណា នាងច្បះច្បង　　ឲ្យអស់ចិន្តា　　អាសូរកំសត់

កាលគេយាត្រា តែពីរអគ្គា ដើរដោយទួលទី ៗ
គិតហើយវិទ្យា លបលួចយាត្រា ដើរដោះចេញខ្ទី
សៀតសឹកលាក់ខ្លួន ពឹងពួនឥតបី កុំឲ្យក្រគ្រី
យុងយល់ឡើយណា ៗ លបមើលបំណាំ គិតគួចចងចាំ
ក្នុងចិត្តអាត្មា ឯងនាងនាថ ស្រីសុវណ្ណា
ឯឈើឈៀបផ្កា ផ្កាយផ្សប់អស់អគ្គី ៗ ទ្រង់ព្រះកន្សែង
គិលាបចូនថ្លែង ថាឱព្រះបង ទ្រង់យាងទៅចោល
ប្អូនយូរគ្គាត់ហោង ព្រះសើយប្អូនរង ទុក្ខទៀបមរនា ៗ
ឈឺឈួលឈៀបឡើង ប៊ីដូចទូវភ្លើង ពលពេលអាត្មា
បើសិនព្រះបង មូលផងប្អូនភ អ្នកនឹងករុណា
រម្ពក់ស្ងួនគ្រង ៗ ឱព្រះម្ចាស់ថ្លៃ ចម្ចខ្ញុំសព្វថ្ងៃ
មិនឲ្យមានហ្មង ឥឡូវប្អូនឈឺ ឥម្លឹងចេះហោង
ប៉ឹងហើយព្រះបង ពុំបានយល់មុខ ៗ ប្អូនមកពីឆ្ងាយ
ព្រាត់ពីនាក់ម្ដាយ នូវនាក់ឪពុក ពូចពង្សស្រំបូរ
គ្រកូលស្រែស្រុក ល្ហើយល្ហែលែងទុក្ខ ពឹងបុណ្យភជា ៗ
ឥឡូវព្រះបង ស្ដេចដោះដៃផង ចោលប្អូនកំព្រា
ប្អូនឥតបើដឹង ពឹងពាក់នណា ក្រៅពីព្រះមហា
ក្សត្រាថ្កើមថ្លៃ ៗ ហើយនាងទួញទៅ ព្រះមាតានៅ
បីតានាយនៃ . តាំងក្រុងអាសុរ៉ ជាបិតាថ្មី

មានមេត្តាក្រៃ កាលនោះនោះណា ៗ ទើបអ្នកម្ដាយ
មួយមិនឃ្លាតឆ្ងាយ ដូចកាលសព្វគ្រា សំអ្នកបីបម
ថ្នាក់ថ្នមបុត្តក្យា ពុំឲ្យអ្នកណា ទទឹងឡើយហោង ៗ
នេះម្ដងបុត្រថ្លៃ ឈឺឈៀបពេកក្រៃ ឯកឯងកន្ទង់
ឥតអ្នកណាមួយ នឹងជួយឡើយហោង កម្មកូន ៗ វង
ទុក្ខតាមវេរា ៗ ជម្ងឺឡប់ ទន់សរសៃសព្វ
ញាប់ញ័រកាយា វង្វែងស្មារតី ចំប្រែប្រឹងថា
អស់នាងទាសា មកជួយចំផង ៗ ប្អូនអើយអ្នកទៅ
អញ្ជើញលួងបួង នៅមាតាហោង ឲ្យស្ដេចមកឆាប់
ប្រញាប់នេះម្ដង ចុំឈឺកន្ទង់ ឥតឯកណានា ៗ
ឯអស់ក្សត្រី ស្ដាប់នាងទេវី សាសងទូលថា
ទៅអញ្ជើញហើយ អ្នកកើយមាតា ស្ដេចទឹងយាត្រា
មកមែនពុំលុង ៗ កុំមាសប្រលឹង សោយសោកទន្ទឹង
រិះរកព្រះអង្គ ប្រុងព្រះស្មារតី ក្សត្រីវរវង្ស
ព្រះមាតាទ្រង់ បណ្ដាំមកណា ៗ នាងស្ដាប់ពាក្យពី
ប្រាំពីរក្សត្រី ទូលទើបនាងថា ប្អូនអើយនេះម្ដង
សំមិនរស់ជា មនុស្សឡើយប្អូនក្យា ប្រាំពីរពីសី ៗ
លុះដល់ជាស់ចុំ ស្ងប់ស្ងាត់ប្រឹងពុំ កំឡុងរាត្រី
នាងរងឈឺផ្ទន់ ទុរុនអង្គស្រី កាន់កាំងស្មារតី

សូមឲ្យសព្វសោះសា ៗ ប្រាំពីរក្សត្រ ស្ទុះចូលទៅខ្ទឹ

ខានព្រះពុទ្ធិតា ខ្លះឡើងជិះផាន់ កំកាន់ប្រាក់

ខ្លះយកហត្ថា គ្រប់កក្រក្សត្រ ៗ ខ្លះចាប់សង្កត់

ខ្លះយកសំពត់ ប៉ុកមាត់ទេវី ឯនាងវលក្ស

ពុំភ្ញាក់ស្មារតី សន្ទប់នៅនៃ បន្ទុំសុវណ្ណ ៗ

ឯព្រះពង្សពុទ្ធ ធង្កលវិសុទ្ធ នៅក្នុងគគិណា

បុណ្យបារមីសល់ លុះដល់វេលា ប៉ុក្សគោមធាយា

បានបរិបូណ៌ហោង ៗ ប្រសូតិចេញចរ ចាកព្រះឧទរ

រុងរឿងកន្ទង ត្រកាលត្រកូល ឥស្សរប្រុះប្រង

អស្ចារ្យក្តាត់ហោង ទឹងព្រះបេស្តា ៗ ពជទិវសថ្ងៃ

ទ្រង់ធ្មរសវែជ នូវព្រះខាន់ថ្វា កន្កវព្រះម្កុជ

ពិសុទ្ធសោភា ក្ដីផ្ទុកទាំងប្រា សាទស្ទួគិសោភី ៗ

បុត្រវត្តុឧត្តម ព្រះឱស្ដហាយុំ ក្សិនអស់ក្សត្រ

យកដៃបិទមាត់ បុត្តវត្ថពីសី ដាក់ក្នុងហិបទ្ទឹ

ទាំងធ្មរខាន់ថ្វា ៗ ហើយហៅទាសី ក្សិបក្សៀវស្រដី

ផ្ដផ្ដាំផ្ដាញ ចូលហាន់យកទៅ កប់នៅអង្គា

កុំឲ្យនរណា ដឹងកិច្ចកល់ឡើយ ៗ ឯមេទាសី

លើកហិបឡើងខ្ទឹ ទូលទៅជាមួង មេឃបំព្រានព្រះ

ខះខកន្ទង គ្រងក្ដីហើយហោង មានអ្នកផងយល់ ៗ

ទ្រុន្ទានគាត់ព្រៃ ដល់ដើមព្រះជ្រៃ និគ្រោធធំសល់
មិនមានមនុស្សម្នា យាត្រាដើរដល់ ស្ងប់ស្ងាត់គាប់គល់
ចូលជីករណ្ដៅ ៗ ហើយកកាយកប់ ស្រេចហើយត្រឡប់
វិលវិញលំនៅ លុះដើរដល់ស្រេច រំពេចចូលទៅ
ចូលនាងជួបនៅ ដំណើរនោះណា ៗ នេះនឹងស្រដី
កាលដែលក្សត្រី ប្រសូតបុត្រា សន្ធប់លុនលុង
ឯអគ្គវិទ្យា លបមើលធីតា សែនសោយសោកសល់ៗ
ហើយឃើញពងបុត្រ ប្រានប្រុសប្រាកដ ល្អល្អះនិមល
ទ្រង់ធរព្រះខាន់ ដាក់ស្បាន់បានយល់ នៃនាងកាចកល
ផ្ញើទោសដ័យ្យា ៗ យល់ទាំងគេដាក់ បុត្រថ្ងៃវល្ក
កង់ហិបនោះណា ៗ យល់ទាំងទាសី ឃ្លាតខ្លីសោះសា
នានាំយាត្រា ចចេញទៅហោង ៗ វិទ្យាគិតភ័យ
អួលអន់ចិត្តក្រៃ ថាឪនេះម្ដង ទុក្ខអើយវើងធ្ងន់
ក្រៃពន់កន្ទង ម្ដេចនឹងរម្ងង រស់រួចជន្លា ៗ
អ្នកមាសកល្យាណ ម្ដេចឡើយសម្រាន ដួលដេកនិទ្រា
មិនដឹងបុត្ររត្ន ខ្ចាយខ្ចាត់ឃ្លាតឃ្លា ចិត្តគេបុស្យា
បំភាត់បាត់បង់ ៗ ខ្ញុំថប់ពេកក្រៃ ណាមួយបុត្រថ្លៃ
ណាមួយព្រះអង្គ ខ្ញុំនឹងតាមបុត្ត ពីសុទ្ធវង្ស
ហាក់ដូចខ្ញុំបង់ អ្នកមាសពុំងារ ៗ

មួយបើខ្ញុំខាន នៅនេះពុំបាន តាមទៅឡើយណា
អាសូរបុត្រថ្លៃ រស់ខ្សែកាចជា ឲ្យយល់កព្ភា
សោះទឹងសង្ស័យ ៗ ចិត្តខ្ញុំចម្បែង ដូចគេជញ្ជីង
បែកជាពីរបី ទ្រូងទ្រុតស្ទើបែក សញ្ជែកទទៃ
រឹងរិះក្រៃក្រៃ ទឹងកាត់ស្នេហា ៗ
មាសស្ងើយអ្នកនៅ ខ្ញុំលាអ្នកទៅ តាមពងបុត្រា
ពុំលុងសឹងឆាប់ ប្រញាប់ម្នីម្នា មកថ្កានអ្នកជា
អម្ចាស់សិរសី ៗ ក្បិននាងវីឡា រត្តរត់យាត្រា
ចេញតាមទៅខ្ចី ដិតដោយទាសា មោហាគេរថី
ទាំងយប់ពត្រី លប់លាក់អាត្មា ៗ ខំដើររុកពន
សរសៀរដោយគៀន ពុំឲ្យទាសា ជីងដើមកិច្ចកល់
ដល់តិចឡើយណា លុះគេយាត្រា វិលវឹងវិញហោង ៗ
វីឡាចូលថ្កាន ក្រោមទិគ្រោធស្ថាន បុត្ររត្នប្រះប្រៀង
ប្រុសប្រាណប្រមៀល នរនៀលនៅហោង ស្រែកយំរពង
ទូញទល់ទុក្ខា ៗ វីឡាក៏យំ ថាមាសឧត្តម
បាបអ៊ីប្អូនណា ចាកមាតាថ្លៃ នៅដោយព្រឹក្សា
តែឯងឯកា ទុរគមឆ្ងាយសល់ ៗ បើព្រះមាតា
ភ្ញាភ្ញាក់អាត្មា មៀងមើលមិនយល់ សំនាងស្រីពៅ
សោកសៅដោរដល់ នេត្រានិមល រកបុត្រពុំឆារ ៗ

| | | |
|---|---|---|
| មួយឯងថ្មី | ផ្កាផ្កាយផ្សប់ឈើ | ពេកពុំទាន់ដា |
| ខ្ញុំគិតទៅហើយ | អ្នកកើយខ្ញុំមហា | ថប់ពន់ពេកណា |
| នឹងអ្នកនេះម្តង ៗ | អ្នកកើយព្រៃស្ងាត់ | ព្រួសឹងមាត់សត្វ |
| យាសយ៉ាំពង | ផុតខ្លួនខ្មោច | លន្ទោចសូរសង |
| ទីទុយមៀមផង | ស្រែកស្រោយមាយា ៗ | ឱអ្នកពេលហ្នឹង |
| សំប្រុសព្រលឹង | វេងវងវេទនា | មួយក្រែងអត់ដោះ |
| ដាច់ពោះមរណា | ក្សិណក្ស័យជន្មា | អាសាសូន្យហោង ៗ |
| ក្សិណនាងវេឡា | ដស់ឡើងមីម្នា | ចាកស្ថាននោះហោង |
| ទៅពាំបន្ទ៉ា | មីម្នាវិលផ្គង | ចារដាវបង់ |
| ស្រះអង្គបុត្រា ៗ | ហើយអាទិស្ថាន | បពិត្រសូមទាន |
| ទិព្វទេព្យព្រឹក្សា | ទោះទេពសោឡស | ខ្ពង់ខ្ពស់សួគ៌ា |
| សម្តេចឥន្ទ្រា | ទរិនកោសី ៗ | សូមអ្នកករុណា |
| ជ្រោមជ្រៃងរក្សា | ឥរសក្វាប្រិ | ឲ្យរួបរសជន្ម |
| បុត្តតន់ពីសី | ដោយតេជៈបារមី | ទេពទាំងសួគ៌ា ៗ |
| នាងផ្សងបណ្តើ | រំពៃមៀងមើល | សព្វព្រៃព្រឹក្សា |
| ក្នុងចិត្តបង់បាំ | ដោយដងមាគ៌ា | នៃទិគ្រោធា |
| កាន់ក្លួបសំគាល់ ៗ | ស្រេចហើយពុំលង់ | រុកពានគ្រេចគ្រង់ |
| ចេញចាកទាំងទាល់ | ចិត្តនាងអល់ឯក | ពារែកពិកល |
| សេចក្តីទំនាល់ | នឹងនៅពុំបាន ៗ | ដល់នេត្រឥតអាក់ |

ហៀរហូរសស្រាក់ ពិតពុំស្រាកស្រាន្ត រូតរត់ឃ្លាតខ្លាញ់
វិលវិញលុះបាន ដល់ប្រាសាទស្ថាន នាំនាងសោភា ។
ឃើញនាងឧត្តម ស្ងៀមស្ងាត់ផ្ទុំ ពុំភ្ញាក់អាត្មា
វិទ្យារឹងទ្រូញ ទំនួញសោកា ទឹងព្រះពុទ្ធិតា
ខ្លោចផ្សាកន្ទួង ។ ហើយវិទ្យាផ្អាប់ សំងំចាំស្តាប់
អស់កិច្ចកល់ផង ក្នុងពោះផ្អុកៗ ឥតសុខប៉ុនល្អង
ឧក៉ីរឹងរង ឈៀបឈឺខ្លោចផ្សា ។ ឯអស់ក្សត្រី
កាលប្រើទាសី សួរថាហើយណា នាំយករូបឈើ
ផ្ញើស្នងបុត្រា ទ្រទ្រាប់កន្ត្រា ថ្កល់ពានសុវណ្ណ ។
លាយលាបលោហិត ផ្ញើហាក់ដូចពិត ជាបុត្រទេវី
ក្សិណនាងវរល័ក្ស ភ្ញាក់ស្មារតី ដឹងព្រះអង្គខ្ញី
ពុំយល់បុត្រា ។ នាងភ្ញាក់គិតព្រួច ពន់ពោះក្រលួច
ហើយដន្ទឹងថា នាងអើយកូនអញ សំឡាញ់ពុំឆា
តើយកទៅណា បាត់បង់សូន្យសល់ ។ សូមនាងទៅយក
កូនស្ងួននោះមក ឲ្យបងបានយល់ សោះបងនេះនៃ
គិតកែអំពល់ ទឹងបុត្រនិមល ពន់ពេកឡើយណា ។
បងព្រុមាត់យំ ពីពោះសូរសំ ជាក់នៅកាម្មា
ប្រាកដទៀងទេ ឥតឯមោហា ឱបុត្រពុំឆា
ជាប្រុសឬស្រី ។ ទើបអស់នាងនោះ សាសងដោយដោះ

ថ្កានវរក្សត្រី ដោយបំណោះនាង បេះខាងសំដី
ព្រះមាសពិសី កុំព្រួយចិន្តា ៗ រាជបុត្រឧត្តម
អស់ទាំងយើងខ្ញុំ ស្ងួនគ្រែងរក្សា ទុកមួយអន្លើ
ឥតបើភ័យា មួយមកពាធា បៀតបៀនយាយី ៗ
ប្ដូរអ្នកគួរគង់ ប្រយ័ត្នប្រាណប្រុង ឯអង្គក្សត្រី
កុំគិតឯបុត្រ ពិសុទ្ធសួស្ដី ជាទេឥតបី
មានហ្មង់ឡើយណា ៗ ឯនាងនាងថ្លៃ ស្មានស្មោះហឫទ័យ
ដូចពាក្យគេថា ពំដឹងគំនិត គេគិតផ្ដន្ទា
ព្រះរាជបុត្រា ដល់តិចឡើយហោង ៗ នាងនាថជយា
ប្រាំពីរភ្គា ចិត្តទ្រុស្ដទ្រើសឃ្នង គិតថាយើងបា
ដូចចិត្តបំណង គួរយើងនេះម្ដង ឲ្យអស់សេនា ៗ
ទៅទូលព្រះបាទ ព្រះបរមនាថ ឲ្យជ្រាបចិន្តា
គិតព្នោះយល់ល្មម ព្រាក់ព្រមគ្រប់គ្នា ទើបតែងអក្ខរា
កក្កូតសេចក្ដី ៗ ដ្បូតសុវណ្ណា ឈើផ្ទុំហិមា
កាលក្រោយចក្រី នាងទឹងសម្រាល កុមារពិសី
សូមព្រះភូមី ជ្រាបព្រះទ័យ ៗ ឈើផ្ទុំពេកពន់
ទុកទុរទ់ ឥតឯឧបមា ក្រាបទូលអញ្ជើញ
សម្ដេចក្សត្រា ថ្កានរាជសេមា កំលង់ឡើយហោង ៗ
ទើបប្រឹកាមាត្យ ចេញចាកសង្វាត តាមព្រះប្រាស់ប្រែង

តាំងនាងសុរិល ប្រាម្ពិលនោះហោង ផ្ដែផ្ដាំពាក្យផង
ស្រេចហើយយាត្រា ៗ ក្រោយនោះនាងគិត ធុញថប់គំនិត
រួសរិះនូវគ្នា ក្រែងព្រះភូធរ ស្ដេចចរមកណា
ហើយព្រះរាជា សន្ធិះសង្ស័យ ៗ ស្ដេចពុំជឿថា
រាជបុត្រពុំងា ឈើដូច្នោះនៃ សំយើងឥតការ
អាសាក្សិណាក្រៃ ទោសនោះធ្ងន់ក្រៃ លើសអ្វីនានា ៗ
ខូះឆ្លើយថាមេ ក្រអ្វីងាយទេ កុំព្រួយចិន្តា
យើងឲ្យទៅរក គ្រូមករួសក៏ ធ្វើសិល្បសាស្ត្រា
ឥឡូវនេះម្ដង ៗ អញព្រួគេថា មានគ្រូឈ្មោះសា
ពូកែកន្ទង គួរយើងប្រើទៅ ខាន់ទៅជាម្ដង
យកទៅព្រមផង កុំការង់នៅ ៗ នាងប្រាំពីរអង្គ
គិតគ្នាពុំលង់ ឡើយរៀបខាន់ទៅ មាសមួយពាន់នែ
សៅដៃទូលទៅ រិះរកលំនៅ នៃលោកគ្រូសា ៗ
ហេតុស្រីបំរើ បង់ល្បាយញាំញី ឆេកឆោកញាក់ស្មា
ពព្រីតពព្រាយ បញ្ចេញបុក្យពា ញ៉ៀងញ៉ង់យាត្រា
ដល់ទីលំនៅ ៗ ចរចូលទៅស្នោះ ឥតមានពិគ្រោះ
ឆ្កែពីព្រុសរ៉ើ តាសីភ័យរត់ ជ៉ោងសំពត់អាវ
មាត់ប្រឹងស្រែកហៅ ពូអើយជួយផង ៗ ឆ្កែពឹតតែដេញ
តាសីរត់ស្ទេញ ស្រែកព្រុំពង គ្រូសាឃើញច្នោះ

ស្ទុះទាញដំបង    ហោលវែងជាម្តង    ត្រូវខ្នងតាសី ៗ
អែនស្អែស្អើរបាក់    ប្រែបេមាត់ធ្លាក់    អង្គុយនៅដី
ណា ឈើណា ខ្វាស    សៀមលែងចេញស្តី    គ្រូសារត់ខ្ចី
ដល់ហើយសួរថា ៗ    សូមទោសអ្នកស្រី    អ្នកមករកអ្វី
ដល់ទីនេះណា    ខ្ញុំឃើញឆ្កែដេញ    ភ័យស្លុតកាយា
ហោលទៅប្រាថ្នា    ឲ្យឆ្កែខ្លាច ៗ    ដំបងរត់ជ្រួស
ត្រូវនាងដូច្នោះ    ហេតុគ្រោះនាងកាច    សូមនាងអត់ទោស
ព្រោះខ្ញុំពុំអាច    បង្អែបង្អៀប    ឲ្យត្រូវនាងឡើយ ៗ
តាសីឆ្លើយថា    ខ្លួនខ្ញុំឯងណា    មកនេះជាត្រើយ
ចំពោះមានការ    លើរូបតាហើយ    ស្ត្រីត្រានត្រើយ
ប្រាពីរប្រើមក ៗ    លោកគ្រូថា    បំរើធិតា
ប្រាម្ពីរពន្ទុក    ភិតភ័យហើយហៅ    ថាអញ្ជើញមក
លើផ្ទះរិះរក    ពិសាស្ងោរសិន ៗ    តាសីក្រោកដើរ
ខូចអស់ដំណើរ    ពុំសូវកាប់កិន    ប្រាសគួចបណ្តើរ
រៀបកន្ទុយក្បិន    មុខក្រហាមឆ្អិន    ដោយអៀនអង្គឯង ៗ
ឡើងដល់លើផ្ទះ    លើកដៃសំពះ    ហើយនាងថាថ្លែង
ថាម្ចាស់ប្រើខ្ញុំ    មករកតាឯង    ឲ្យជួយតាក់តែង
ដោយមានប្រាថ្នា ៗ    ចង់ឲ្យព្រះបាទ    បរមនរនាថ
ព្រះទ័យក្រោធា    បណ្តាញបរបង់    អង្គសុវណ្ណា

ឲ្យទ្រង់ស្នេហា តែនាងប្រាថ្នា ៗ បើបានដូច្នេះ
រង្វាន់តាំងនេះ ព្រះនាងនារី ផ្ដាំថាឲ្យខ្ញុំ
ជូនលោកតាខ្វី សូមតាប្រណី ជួយឲ្យសម្រេច ៗ
គ្រូសាត្រហើយ តតបឆ្លងឆ្លើយ . ថាការតូចតិច
នាងកុំព្រួយអ្វី មុខជាសម្រេច ខ្ញុំដឹងហើយកិច្ច
នេះធ្លាប់ធ្វើញយ ៗ ទាសីស្ដាប់ជាក់ ត្រេកអរឥតអាក់
ខាន់ទៅហុចឲ្យ គ្រូសាទទួល ញញឹមបែរក្រោយ
ស្រែកហៅយាយប៉ោយ យកជាប្រញាប់ ៗ
បានហើយគ្រូសា សុះទៅមីមា រួសរៀបយ៉ាងឆាប់
ដំកល់ដំកើង គ្រូឡើងអោយច្បាប់ អញ្ញើញហើយប្រាប់
ដោយដំណើរណា ៗ ស្រេចចាប់យកយាម ស្ពាយចរចុះក្វាម
ទៅតាំងទ្វេហា លុងតិចបានដល់ មណ្ឌលប្រាងប្រា
សាទសំសោភា បរចូលទៅហោង ៗ នាងយល់ទាសា
បណ្ដើរទាំងតា នាងអរកន្លង ស្រែកហៅឲ្យឡើង
តានឹកភ័យផង ដើរទិនគោង ៗ ខ្វាបព្រះបារមី ៗ
នាងត្រាស់ហៅពៅ ថាខ្ញុំឲ្យហៅ តាមកនេះខ្វី
ប៉ុនប៉ង់ប្រាថ្នា ឲ្យតាប្រណី ដូចមេទាសី
ប្រាយប្រាប់នោះណា ៗ បើបានដូចចិត្ត ប្រាថ្នាយើងគិត
ព្រួយអ្វីឡើយតា ខាន់ទៅរង្វាន់ គ្រប់គ្រាន់ជាតិជា

ដង្វាយគ្រូតា តាមចិត្តបំណង ៗ ឯតាបានស្តាប់
ក្សត្រឯកសព្វ បន្ទូលប្នោះហោង ពេញចិត្តអរឯង
ពុំក្រែងប៉ុនល្អង ទើបតាទូលស្នង ប្រាំពីរធីតា ៗ
បពិត្រស្រីថ្លៃ កុំព្រួយព្រះទ័យ ខ្ញុំនឹងជានា
ធ្វើតាមព្រះទ័យ បានដូចប្រាថ្នា នាងស្តាប់គ្រូថា
ពេញចិត្តជឿក្រែ ៗ ហើយគ្រូបង្គាប់ ឲ្យរៀបប្រដាប់
ដោយក្បួនសស្ត្រសៃ ទៀនធូកអក្ក សំពត់សរនៃ
ចិទប្រាក់បីប្រពៃ ចាចាំហើយណា ៗ ទើបឲ្យធ្វើបែង
ខ្វល់ខ្វាយតាក់តែង សូន្យប្រួពជា ដាក់ចំណីទ
ត្រកាលញាំភ្ជា បាយទឹកនូវស្រា ប្រនួបផងក្តី ៗ
ក្សិនមានទាសា ពីរបីកាយា ចចូលទៅខ្ចី
នាងបន្ទូលថា ហងកុំស្រដី ប្រាប់ព្រះវរបី
ថាតាមកហោង ៗ អញឲ្យរង្វាន់ មាសប្រាក់គ្រប់គ្រាន់
កំបែងសូរសង អកយាយចាស់ទុំ នៅព្រះស្នំផង
គ្រប់គ្នាជាម្តង សឹងបានទ្រព្យ ៗ ហើយនៅស្ងៀមស្ងាត់
កន្តើយបាត់មាត់ ពិតពុំនាំពា ខ្វះគិតអាណិត
ស្រីរត្នមហិមា ពុំហានចរចារ ខ្វាចដល់ជីវ ៗ
ពុំហ៊ានយកទ្រព្យ ហើយវិលត្រឡប់ មកផ្ទះវិញខ្ចី
អង្គុយគន់គិត អាណិតក្សត្រី ប្រសើរស្រស់ស្រី

ពុំដឹងអាត្មា ៗ   វីកាណ្ណោះនៃ   សច្ចាស្រីថ្លៃ
នាងពុំដឹងជា   កែវសុវណ្ណី   ប្រសូតិបុត្រក្វា
យប់នាងនិទ្រា   ជាសុខសួស្តី ៗ   នាងសុបិនជាក់
ដីញាក់មួយផ្ទាក់   ត្រូវកក្រ្តស្រ្តី   ហើយពីងពាងទំ
យុំព្យួខ្លាំងក្រៃ   ក្រោមក្រែស្រីថ្លៃ   នាងនាដនិទ្រា ៗ
ក្សត្រីឧត្តម   តើនបាកបន្ទុំ   ស្រាងស្រេចសុរិយា
ទន្ទឹងបុត្រី   ប្រិមប្រិសោភា   ឱសុវណ្ណា
សម្លាញ់ម្តាយអើយ ៗ   មិនមកគាល់ហៅ   ឈឺផ្ទៃឬនៅ
ម្តេចទៅនាងអើយ   ក្សិនព្រះជីទី   ក្សត្រីគ្រានត្រើយ
គិតដូច្នោះហើយ   នាងប្រើទាសា ៗ   ចូរហែងដើរទៅ
សួរនាងកូនតៅ   កែវសុវណ្ណា   ម្តេចបាត់សូន្យសល់
ពុំយល់កត្តា   ប្រសូតិបុត្រក្វា   ឬនៅឡើយហែង ៗ
ថាបើសម្រាល   បុតស្ងួនត្រកាល   អញទឹងបរគ្គង
ទៅជួយរួមពក់   ពិភាក់ស្ងួនត្រង់   ឥឡូវនេះហែង
ពុំលង់ឡើយណា ៗ   កាលណោះទាសី   ពីពង្សឃ្លាតខ្ចី
ចរចេញយាត្រា   ទៅដល់ប្រាសាទ   នាងនាដថ្លៃថ្លា
ពុំយល់ដេយ្យា   ដូចរៀនសព្វដង ៗ   យល់តែធិតា
ប្រាម្ពីអគ្គា   ស្ថិតនៅនោះហែង   សៅពីរបន្គុំ
ប្រណម្យទូលស្នង   ក្សត្រីប្រះប្រួង   ស្តេចគង់ឯណា ៗ

ជៀតព្រះជននី ប្រើខ្ញុំមកខ្ចី សួរវរជេយ្យា
ហើយសៅពីរថ្ងៃ ដូចនាងសព្វា សុខសប្បាយជា
ទេព្វស្ដេចទៅ ៗ ប្រាំពីរនារី ស្ដាប់សាសំដី
ក៏យកគិតពេកក្រូវ ជុំនុំគ្នាថា កូនគ្រាឥឡូវ
យើងគិតឲ្យត្រូវ ទាសីនេះផង ៗ នាងយកសុវណ្ណ
ទម្ងន់មួយពាន់ ដំឡឹងជាម្ដង ឲ្យមេទាសី
ទ្វេហានេះហោង នាងថាហៃបង អាសូរប្អូនក ៗ
បងយកឧបាយ ប្រស្នាដោះស្រាយ ទូលព្រះមាតា
កុំថាសម្រាល បុត្ររត្នឡើយណា តាមតែបងថា
ឲ្យសំរេចក្ដី ៗ មាសទាំងមួយពាន់ ប្អូនឲ្យរន្ទាន់
សូមបងប្រណី កុំឲ្យគាំគង់ ទឹងល្អងធូលី
ព្រះវរជិនី ស្ដេចទ្រង់ក្រោធា ៗ សៅពីរលោកលន់
ពិតពុំគិតគន់ ទោសទាស់អាត្មា មើលយល់សុវណ្ណ
មួយពាន់នោះណា អរឯងមហិមា ទទួលយកហោង ៗ
ហើយវិលយាត្រា ទៅទូលធិតា ពីនាងច្បាស់ច្បង
ដោយចំណេះនាង បេះដាងកក្រុង ថាបុត្តស្ងួនគ្រង
កែវសុវណ្ណា ៗ នាងថ្វាយបង្គំ មកក្សត្រឧត្ដម
ជាព្រះមាតា ឯកជបុត្រថ្លៃ ប្រពៃសោភា
ឥតមានពេលា នាងនៅគៀមក្សាន្ត នាងស្ដាប់ទំនូល

សៅដៃក្រាបទូល ពីបុត្រកល្យាណ ទ្រង់ព្រះអំណរ
សាទរគន់ប្រាណ រុះរាយឥតមាន មន្ទិលឡើយណា ៗ
យើងនូវដំណាល ឯអគ្គភូបាល ស្តេចគន់ព្រឹក្សា
លន់លុះស្រេចស្រាន់ បំពានសុរិយា តើនពាក់ក្រឡា
បន្ទុំទិព្វថ្ងៃ ៗ ស្រោបស្រេចពុំលុង ស្តែងស្តេចឡើងគង់
លើដំរីដៃ ទាហានអាសា ណាស់ណាន់ក្រាស់ក្រៃ
វិលវិញមកព្ង ព្រះរាជធានី ៗ សម្តេចភូធរ
ពុំបានឈប់ឈរ ឡើយព្រះចក្រី រលឹកមកស្មាន
គិមានសួស្តី រលឹកប្អូនស្រី កែវសុវណ្ណា ៗ
ស្តេចថាឱមេ មាសនៅជាទេ ប្អូនពាំងា
ប្រសូតិបុត្រថ្ងៃ ប្រពៃសោភា ប្អូនើយបងមហា
ថប់ពេកកន្ទួង ៗ ឯអគ្គសេនា ដែលនាំអក្ខរា
រួតរត់ដោយដង ក្បួនទៅប្រទះ នឹងព្រះប្យះប្យន
បរបួលត្រសង ក្រញូក្រាបវន្ទា ៗ ឱនអគ្គលំអុត
ថ្វាត់ថ្វាយសំបុត្រ ហើយទើបទូលថា ពីនាងស្រស់ស្រិល
ប្រាំពីរអគ្គា ប្រើខ្ញុំមកណា អញ្ជើញចក្រី ៗ
ថាសូមប្រញាប់ ធិប្បាយសាសព្វ សឹងមានសេចក្តី
គន់នៃសំបុត្រ ប្រាកដឥតបី ខ្វះឡើយភូមី
សូមជ្រាបទេព្យា ៗ ស្តេចស្តាប់អាមាត្យ ទូលទើបព្រះបាទ

ត្រាស់មកម្នីម្នា   សួរពីប្អូនស្រី   ប្រិមប្រិយសោភា
ប្រសូតិបុត្រា   ប្អូននៅនេះម្តង ៗ   អាមាត្យក្រញ្វក្រាប
សិរសាទន្ទាប   ប្រណម្យទូលស្នង   ក្សត្រីរត្នថ្លៃ
ឈឺផ្ទៃហើយហោង   ក្រោយខ្ញុំបរផ្គង   ពងឹងឡើយណា ៗ
ស្តេចទ្រង់ទតយល់   លាយលាក់សំគាល់   ជ្រាបហើយក្សត្រា
ព្រួយព្រះហឫទ័យ   ពេកក្រៃមហិមា   នឹងព្រះពុទ្និតា
ទាំងបុត្រពីសី ៗ   ក្សត្រថ្លៃឧត្តម   កាលនោះស្តេចពុំ
ផ្សងឡើយកូមី   សង្វាតស្រួតស្រាក   ព្រះភក្ត្របក្រិ
អ័បអស់រស្មី   ក្រៀមក្រមក្តាត់ណា ៗ   ផ្លូវឆ្ងាយពេកក្រៃ
កំណត់បីថ្ងៃ   ឆ្ងាប់វែងយាត្រា   ស្តេចត្រេបមួយថ្ងៃ
កាត់ព្រៃព្រឹក្សា   រសៀលសុរិយា   ដល់ព្រះនគរ ៗ
ក្សត្រក្សាន្តធិបតី   ចុះចាកអំពី   គុជ្ជនទ្រង់បរ
ឡើងលើប្រាសាទ   ព្រះបាទភូធរ   មូលមួយនៅបរ
រិពារពលសេនា ៗ   ក្សិណឯនាងនាជ   ប្រាំពីរជួជាតិ
អរឯងម្នីម្នា   ប្រដាប់ព្រះអង្គ   ពុំលុះយាត្រា
ទទួលព្រះមហា   ក្សត្រក្សាន្តដៀសដៃ ៗ   ហើយយករូបះឈើ
ថ្នាក់ថ្នមអំពើ   មកថ្វាយក្សត្រថ្លៃ   ទូលថាពងបុត្រ
ពិសុទ្ធល្អក្រៃ   ទន្ទឹងសព្វថ្ងៃ   ចង់ជិះគុជ្ជា ៗ
ស្តេចស្តាប់ភ្ញាក់   អៀនអន់ដាក់ភក្ត្រ   ខ្មាសអស់សេនា

ដូចយកព្រះខាន់ កាប់កាត់កេសា វៀលរាស់ទឹក
ឈឺឆៀបកន្ទុង ៗ ហាក់ដូចអគ្គី ពេលដុតកាយី
ក្តៅក្តាត់ពេកហោង ហេតុសិល្បសាសសែ ធុតក្រៃកន្ទុង
ឲ្យព្រះច្បះច្បង រសាយក្រៃផា ៗ ហើយនាងឲ្យប្រែ
ព្រះច័យស្អប់ឯង នាងសុវណ្ណា រង្គើងសូន្យសល់
ដោយនៅមាយា ទិព្វមន្តនោះណា ធុតធាប់ក្តាត់ហោង ៗ

## ផេះបទពំនោល

កាលណោះសម្តេចខត្តិយា ត្រូវស្នេហ៍មាយា
អំពើអំពល់ក្នុងប្រាណ គានតឹងព្រះច័យពុំមាន
អាសូរគលព្រាណ តិចតួចដល់ប៉ុនកេស្សី ៗ
ក្រេវក្រោធគិពេធខ្ញាំងក្រៃ ញ័រអស់ឥន្ទ្រិយ៍
រន្ធន់ទាំងព្រះច័យព្រា ៗ ទតទៅពងបុត្រពុំអា
ឈើដូច្នោះណា ករនិរដ្ឋលក្តៅក្តាត់ ៗ
ឥតអ្នកណាទឹងហានឃាត់ សោតសឹងសៀមស្ងាត់
ទូរន់ពព្រានគ្រប់គ្នា ៗ ស្តែងស្តេចពុំពិភាក្សា
ហើយប្រើសេនា ទៅចាប់សម្តេចមហេសី ៗ
ថាវើយអស់ពួកសេនីយ បូរចាប់កុំបី
ផ្សូផ្សងឲ្យលន់ឡើយណា ៗ ទៅចាប់នាងសុវណ្ណា
មកហើយនាំគ្នា ប្រួតកាប់សម្លាប់នេះឥឡូវ ៗ

ទុនពរសេរិធិអាស្រូវ
កូនកើតពុំត្រូវ
ដោយនៅគន្ធធម៌ថា ៗ
កាលនោះពេជឃាតម្នា
ថ្វាយបង្គំលា
រលះរលាំងដើរដល់ ៗ
លើកដៃដោមដាក់ដំកល់
សិរសាមណ្ឌល
បង្គំសម្តេចពុទ្ធិតា ៗ
បពិត្រក្សត្រីថ្លៃថ្លា
ព្រះរៀមពជា
ស្តេចខ្ញាល់ពន្ទឹកក្តាត់ហោង
ប្រើយើងខ្ញុំមកនេះម្តង
ត្រាស់ឲ្យចាប់ចង
ទាញទាក់ទំលាក់យកទៅ ៗ
សម្លាប់ឆាប់ ៗ និតនូវ
កណ្តាលព្រៃជ្រៅ
អាសាអាសោចបោះបង់ ៗ
នាងស្តាប់សព្ទសេនាផង
នាងគិតលន់លង់
ញ្ញើអគ្គរន្ធត់មហិមា ៗ
នាងត្រាស់ថាហៃសេនា
ទោសអ្វីក្សត្រា
ស្តេចខ្ញាល់ពន្ទឹកពេកសល់ ៗ
ពីពីចារណាឲ្យយល់
អស់អាចិកិប្ចកល់
អំពើអំពល់ពាក្យពេជ ៗ
អញផតគ្គាំគ្គងដល់តិច
ប្រការកល់ម្តេច
ព្រះបាទព្រះបងស្តេចខ្ញាស់ ៗ
ក្សណ្ណាះពេជឃាតថាកាល
អម្ចាស់ស្តេចខ្ញាល់
ដ្បិតនាងប្រាំពីរក្សត្រី ៗ
ទូលថាពជបុត្រពីសី
កើតកាឡកិណី
សម្រាលមកមិញជាឈើ ៗ
ហេតុនោះស្តេចខ្ញាល់ឲ្យធ្វើ
ទោសទុក្ខអំពើ

អំពល់ផ្សិតបុត្រពំនាំ ។ នាងស្ដាប់សាសព្វភា
ពេជឃាតទូលថា ស្រងាក់ស្រងិល់អង្គស្រី ។
គិតបុត្រពិសុទ្ធសួស្ដី វង្វេងស្មារតី
ស្រយុតស្រយ៉ាកអស់អង្គ ។ ម្ដាយស្មានគេពោលត្រឹមត្រង់
ពុំដឹងលលួង បង្វែងបង្វែរវៀចវេ ។
ម្ដាយព្ធមាត់មិត្តមាសស្នេ នេះឥឡូវសុំគេ
បំបាត់ជីវិតបួនក្ខា ។ ម្ដាយពុំដឹងកលមារយា
សូន្យសោះទេណា ទើបដឹងដោយពាក្យពេជឃាដ ។
នាងទួញទំនួញបីអានាង ក្សណ្ណោះពេជឃាត
ពុំផ្សងឲ្យលុងឡើយនៃ ។ អញ្ជើញសុវណ្ណស្រីថ្លៃ
សូមចាប់ចុងដៃ ពាំបេរទឹងទ្រង់ករុណា ។

(សង្ខេបតែប៉ុណ្ណោះ)

ខ្សែ៥ ដើម សេនាតាំង៤ចូលសូមទោស

កណ្ដាល នាងចំប៉ាថោងទៅដល់នគរសិងហ៊ុន

ពួកយក្សខឹងគិតលើកគ្នាមកវាយកំទេចនគរហោមន្ទ

ចុង ជ័យដេតពជាទៅតាមនាងចំប៉ាថោងវង្វេងផ្លូវ

# សៀវភៅដែលផ្សាយចេញពីគេហស្ថាន គឹម-គី

រឿងព្រះថោងនាងនាគទី ១ ដល់-៦ . . . ១ សៀវភៅថ្លៃ ១០៛០០
ទេវតាភាសិតនឹងពុទ្ធភាសិត . . . . . . . . ,, ៨៛០០
សម្ភារសិក្ខាបទ គោលសិក្សាជំនួយធម្មវិន័យ . ,, ១២៛០០
វេយ្យាករណបាឋទី ១ . . . . . . . . . ,, ១៨៛០០
,, ,, ទី ២ . . . . . . . ,, ១៧៛០០
វេយ្យាករណ៍ខ្មែរ . . . . . . . . . ,, ១៣៛០០
លេខទៀរ៍ . . . . . . . . . . . ,, ១៥៛០០
បត្តិទានាទិគាថា គឺឥមិនាប្រែ . . . . . . ,, ៦៛០០
ធម្មបញ្ហា . . . . . . . . . . ,, ៦៛០០
ប្រវត្តិអរហន្តកធាតុ . . . . . . . . ,, ៦៛០០
សមាធិនិទ្ទេសសង្ខេប . . . . . . . . ,, ៣០៛០០
ប្រស្នាគហបដិបត្តិ. . . . . . . . . . ,, ១៨៛០០
វិធីប្រែបាលី . . . . . . . . . . ,, ២៥៛០០
ប្រស្នាអភិធម្ម . . . . . . . . . ,, ២៥៛០០
ប្រស្នាត្រៃលក្ខណ . . . . . . . . . ,, ២៥៛០០
សាមណេរវិន័យបញ្ហា . . . . . . . . ,, ១៨៛០០

សៀវភៅកំពុងតែបោះពុម្ព ឬប្រុងនឹងបោះពុម្ពតទៅ

រឿងដំបងក្រញូង-ក្អាក្រែក-បក្សីចាំក្រុង -រឿងមេទ័ពឥន្ទ្រីស
រឿងព្រះបាទអជាតសត្រូវ
រឿងទិព្វមានុទេវទត្ត រឿងព្រះសុវណ្ណវង្ស

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេក្រង់ ភ្នំពេញ

ជិតរោងកុន ព្រហ្មបាយ័ន ពីខាងកើតផ្ទាល់

---

## សេចក្ដីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលបង្ក្របសៀវភៅ មានជាព្រះពុទ្ធរូប រូបថតផ្សេងៗ គឺ ព្រះរូបព្រះករុណា ទាំងសម្ដេចសង្ឃនាយកជាដើម ទាំងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដិកា ឆាយា សំបុត្រកំណើត កាតកូនសិស្សទាំងសៀវភៅបារាំង-ខ្មែរផ្សេង ៗ ជាច្រើន ។

សូមនិមន្ត ទាំងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រី ។

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសំ ។

ព.ស. ២៤៩៦ គ.ស. ១៩៥៣

ថ្លៃ ១២៛០០

) រោងពុម្ព ភិក-ភ័ ភ្នំពេញ (